**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការប្រើប្រាស់ដីក្នុង ឃុំកាចូន

## ឆ្នាំ ២០០៩-២០២២

## ស្រុកវើនសៃ ខេត្តរតនគិរី



**រៀបចំដោយ:** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយ:** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

**ខែ ធ្នូ ឆ្នាំ ២០០៩**

# មាតិកា


**អារម្ភកថា** ០៣

**សេចក្តីផ្តើម** ០៤

**ជំពូក១៖ ពត៌មាននិងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ០៥

**១.១ ស្ថានភាពទូទៅ** ០៥

១.១.១ ទីតាំងរដ្ឋបាល ០៥

១.១.២ ប្រជាសាស្រ្ត ០៦

១.១.៣ ភាពគ្មានដីធ្លី ០៨

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ៩

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ១០

១.១.៦ ស្ថានភាពសុខាភិបាល ១១

១.១.៦.១ ផ្នែកសុខាភិបាល ១១

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ១២

**១.២ ស្ថានភាពភូមិសាស្រ្ត** ១៤

១.២.១ ទីតាំងភូមិសាស្រ្ត ១៣

១.២.២ អាកាសធាតុ ១៤

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ១៥

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ១៦

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ១៦

១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី ១៧

១.៣.៣ ស្ថានភាពកម្មកសិកម្ម ១៧

១.៣.៤ ធនធានធម្មជាតិ ២០

១.៣.៤.១ ធនធានព្រៃឈើ ២០

១.៣.៤.២ ធនធានជលផល ២១

**១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ២១

១.៤.១ ទីផ្សារ និងតំលៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ ២១

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ២១

១.៤.៣ ឱកាស និងឧបស័គ្គ ២២

**ជំពូក២: ការវិភាគតំរូវការសំរាប់អនាគត** ២៣

**២.១ តំបន់រសើប** ២៣

**២.២ ការប្រឈម/ ឧបសគ្គ** ២៣

**២.៣ តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំកាចូន** ២៤

**២.៤ តំរូវការដីសំរាប់អនាគត** ២៥

២.៤.១ ប្រជាសាស្ត្រ ២៥

២.៤.១.១ អត្រាកំណើន ២៥

២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ២៦

២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ២៦

២.៤.៣ តំរូវការដីកសិកម្ម ២៧

២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ២៨

២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ២៨

២.៤.៥.១ តំរូវការសាលារៀន ២៩

២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ២៩

២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ៣០

២.៤.៥..៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព ៣០

**ជំពូក៣: ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩ ដល់ ២០២២** ៣២

**៣.១ ស្ថានភាពដី សក្តានុពលដី និងតំរូវការដី** ៣២

៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ៣២

៣.១.២ តំរូវការដីតាមប្រភេទ ៣២

**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់ដី** ៣៣

៣.២.១ ការវិភាគអន្តរអំពើ ៣៣

៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត ៣៤

៣.២.៣ បញ្ញត្តិលើការប្រើប្រាស់ដី ៣៥

# អារម្ភកថា

អស់រយៈពេលយូរឆ្នាំមកហើយ បណ្តាឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជាបានទទួលរងនូវសង្គ្រាមដែលធ្វើអោយការគ្រប់គ្រង និងជីវភាពរបស់ប្រជាជនជួបការលំបាកយ៉ាងខ្លាំង ក្នុងនោះរួមមានឃុំកាចូនស្រុកវើនៃសែផងដែរ។ ក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩ ប្រជាជនបានរស់នៅក្នុងស្ថានភាព ពឹងផ្អែកលើធនធានធម្មជាតិតែមួយចំណែក តូចប៉ុណ្ណោះ។ ដោយសង្កេតឃើញស្ថានភាពយ៉ាងដូច្នេះ ក្រុមប្រឹក្សាឃុំកាចូន ដោយមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈក្រោមការជួយគាំទ្រ ពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកវ៉ឺនសៃ (D_LUP) សហការចូលរួមសម្របសម្រួល ពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ខេត្តរតនគិរី (P_LUP) និងគាំទ្រ បច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី (Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាក ប្រចាំនៅក្នុងប្រទេសកម្ពុជាបានរៀបចំចេញជាសៀវភៅផែនការនេះឡើង ក្នុងគោលបំណងចំបងគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ និងសំរាប់ប្រើប្រាស់ ក្នុងការរៀបចំអភិវឌ្ឍន៍ឃុំទាំងមូល សំរាប់រយៈពេល១៥ឆ្នាំ (២០០៨-២០២២) អោយចំទិសដៅ និង ស្របតាម គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការសំដៅពង្រឹងអភិបាលកិច្ចល្អ របស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

ក្រុមប្រឹក្សាឃុំកាចូន សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាក ប្រចាំនៅក្នុងប្រទេសកម្ពុជា ដែលបានផ្តល់ថវិកាជំនួយសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីឃុំកាចូន ចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តរតនគិរី ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការនេះក៏អាចនឹងមិនទទួល បានភាពជោគជ័យផងដែរ បើសិនពុំមានការចូលរួមពីមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពរដ្ឋបាលមូលដ្ឋាន រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម មន្ទីរបរិស្ថាន ខេត្ត។

ក្រុមប្រឹក្សាឃុំកាចូន ក៏មិនអាចបំភ្លេចបានផងដែរ នូវការជួយឧបត្ថម្ភ គាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្តី និងបច្ចេកទេសអនុវត្តផ្ទាល់លើការងាររៀបចំផែនការប្រើប្រាស់ដីពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ( P_LUP ) ថ្នាក់ស្រុក (D_LUP) និងក្រុមការងារថ្នាក់ជាតិ របស់សមាសភាគរៀបចំដែនដី។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពី ស្ថានភាព និងតម្រូវការ ព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ឃុំកាចូន ហើយនឹង បង្ហាញនូវទឹកចិត្តសប្បុរសធមិដ៏ថ្លៃថ្លាតាមរយៈការចូលរួមផ្តល់នូវសំភារៈ និង ថវិកាសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាម គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

ឃុំកាចូន,ថ្ងៃទី...02....ខែ...04......ឆ្នាំ ២០១០

**មេឃុំ កាចូន**

ឆាយ-សុំ

# សេចក្តីផ្តើម

ឃុំកាចូន ស្រុកវើនសៃ ខេត្តរតនគិរី ស្ថិតនៅក្បែរទីប្រជុំជនស្រុកតាមដងទន្លេសេសាន្តប៉ែកខាងជើង មានចំងាយ ៧គីឡូម៉ែត ពីសាលាស្រុកវើនសៃ បើគិតពីខេត្តមកឃុំកាចូន មានចំងាយ ៤០គីឡូម៉ែត។ ហើយឃុំនេះ បើពិនិត្យជាក់ស្តែងនៅទិសខាងកើតឃើញមានភ្នំធំមួយដែលលាតសន្ធឹងទទឹងផ្ទៃពីទិសខាងជើងទៅទិសខាងត្បូង។ ស្ថានភាពភូមិសាស្ត្រឃុំកាចូនអំណោយផលដល់ប្រជាជនក្នុងការប្រកបមុខរបរកសិកម្ម ដូចជា ដាំកូនឈើ នេសាទ ដំណាំហូបផ្លែ និងដំណាំផ្សេង ៗ ទៀត និងការចិញ្ចឹមសត្វ រុករកអនុផលព្រៃឈើជាដើមព្រោះឃុំនេះសំបូរដោយ ធនធានធម្មជាតិដូចជាព្រៃឈើ សត្វព្រៃ ផល-អនុផលព្រៃឈើនិងផលផ្សេងៗទៀតជាច្រើន ។ ធនធានដែលមាន តំលៃទាំងនេះបានត្រូវបាត់បង់បន្តិចម្តងៗដោយក្រុមជនខិលខូចមួយចំនួន និង ដោយការប្រើប្រាស់មិនសមស្រប របស់ ប្រជាជនក្នុងមូលដ្ឋាន ដែលជាហេតុធ្វើអោយទ្រព្យសម្បត្តិរបស់ខ្លួនថយចុះគួរអោយបារម្ភ សំរាប់កូនចៅ ជំនាន់ក្រោយៗ ទៀត។

ដោយពិនិត្យឃើញដូចនេះ ក្រុមប្រឹក្សាឃុំកាចូន រួមជាមួយសមាជិក គ.ផ.ផ និងប្រជាជនក្នុងឃុំមាន គោលបំណង បង្កើតផែនការ ប្រើប្រាស់ដីឃុំដើម្បីធានាដល់ការរស់នៅ និងនិរន្តរភាព នៃធនធានធម្មជាតិនិង ការ ប្រើប្រាស់នូវធនធានទាំងនោះ ប្រកបដោយតម្លាភាព និងមាន ប្រសិទ្ធិភាពខ្ពស់ ។

ផែនការប្រើប្រាស់ដី ជាប្រភេទផែនការដែលមិនអាចខ្វះបាន ពីព្រោះវាជាឧបករណ៍ឆ្លុះបញ្ចាំងពីបញ្ហា និង តំរូវការចាំបាច់របស់ប្រជាពលរដ្ឋ លើវិស័យទាំងប្រាំដូចជាសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិនិងបរិស្ថាន ផ្នែក សេវាកម្មរដ្ឋបាលនិងសន្តិសុខ ផ្នែកយេនឌ័រ ធ្វើយ៉ាងណាអោយឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពក្នុងការ ចូលរួមចំនែក លើកកំពស់ជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋអោយកាន់តែល្អប្រសើរឡើងជាងមុន បើនិយាយជារួមវិញ ផែនការប្រើប្រាស់ដីឃុំ ជាឧបករណ៍មួយដ៏សំខាន់ដែលជួយដល់ក្រុមប្រឹក្សាឃុំក៏ដូចជាខេត្ត ទាំងអស់នៅថ្នាក់ក្រោមជាតិក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរ ភាព និងប្រសិទ្ធភាព ។ ដូច្នេះផែនការប្រើប្រាស់ដីឃុំជាការងារស្នួលសំរាប់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេស អាជ្ញាធរដែនដី នឹងមានមូលដ្ឋាន កាន់តែគ្រប់ជ្រុងជ្រោយក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីទៅក្នុងផែនការ អភិវឌ្ឍន៍ឃុំនៅថ្នាក់ មូលដ្ឋានដោយ ធ្វើសមាហរកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តក្នុងការកសាងផែនការ អភិវឌ្ឍន៍ឃុំដោយមាន ការចូលរួមពីគ្រប់ ភាគីពាក់ព័ន្ធនានាដើម្បីធ្វើអាយផែនការអភិវឌ្ឍន៍ឃុំទទួលបានលទ្ធផល ល្អប្រសើរ។

# ជំពូកទី១

## ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ កាចូន

## ១.១ ស្ថានភាពទូទៅ

ឃុំកាចូនជាឃុំមួយនៃស្រុកវើនសៃឃុំនេះមានផ្ទៃក្រឡាទំហំ **៨០៧៦ ហិកតា** ។ ដែលពីមុនមកភូមិសាស្ត្រនៅទីនោះមានអូរមួយឈ្មោះ អូរកាចូនបានមានតាំងពីយូរយារណាស់មកហើយ ហើយមានភូមិមួយនៅទីនោះយកឈ្មោះតាមឈ្មោះអូរគឺភូមិកាចូន ។ ក្រោយមកភូមិកាចូននេះបានចែកចេញជា ២ភូមិ គឺភូមិកាចូនលើ និងភូមិកាចូនក្រោម ហើយក្រោយមកទៀត បានកើតចេញជាភូមិបន្តបន្ទាប់ទៀតគឺភូមិកាឡឹម ភូមិវ៉ៃង ភូមិវ៉ាយ និងភូមិទៀមលើ ។ ភូមិទាំង៦បង្កើតបាន ជាឃុំមួយដោយសន្មត់យកកាចូនជាឈ្មោះឃុំ ។ ឃុំនេះមានទីតាំងស្ថិតនៅភូមិកាចូនក្រោម ជាប់តាមបណ្តោយដង ទន្លេសេសានមានសណ្ឋានដីជាតំបន់វាល និងខ្ពង់រាប ។

### ១.១.១ ទីតាំងរដ្ឋបាល

ឃុំកាចូន មានចំងាយ ៧គីឡូម៉ែត ពីទីរួមស្រុកវើនសៃ និង ៤០គីឡូម៉ែត ពីទីរួមខេត្ត។ ឃុំនេះមានភូមិចំនួន ៦ គឺភូមិកាចូនក្រោម ភូមិកាចូនលើ ភូមិកាឡឹម ភូមិទៀមលើ ភូមិវ៉ៃង ភូមិវ៉ាយ

ឃុំកាចូនមានព្រំប្រទល់ :

- ខាងជើង ជាប់នឹង ឃុំកុកឡាក់ ស្រុកវើនសៃ
- ខាងត្បូង ជាប់នឹង ឃុំកាឡៃ ស្រុកអូរជុំ
- ខាងលិច ជាប់នឹង ឃុំប៉ុង ស្រុកវើនសៃ
- ខាងកើត ជាប់នឹង ឃុំកោះពាក្យ ស្រុកវើនសៃ

| | | |
|---|---|---|
| ខេត្ត | រតនគិរី | |
| ស្រុក/ក្រុង | វើនសៃ | |
| ឃុំ/សង្កាត់ | ឈ្មោះ កាចូន | លេខកូដ: ១៦០៩០៤ |
| ចំនួនភូមិ | ៦ ភូមិ: **ភូមិកាចូនក្រោម ភូមិកាចូនលើ ភូមិកាឡឹម ភូមិទៀមលើ ភូមិវ៉ៃង ភូមិវ៉ាយ** | |




***រូបភាព១:*** ផែនទីបង្ហាញទីតាំងរដ្ឋបាលឃុំកាចូន

## ១.១.២ ប្រជាសាស្ត្រ

តាមរបាយការណ៍ដែលទទួលបានក្នុងឆ្នាំ២០០៨ បង្ហាញថាចំនួនប្រជាជនសរុបក្នុងឃុំមានចំនួន២០៦៩នាក់

ចែកចេញជា ៤៦១គ្រួសារ ក្នុងនោះស្ត្រីមានចំនួន ១០០១នាក់ ។ ដង់ស៊ីតេជាមធ្យម១០ នាក់ក្នុង១គ.ម² ប្រជាជនចំណូលស្រុកស្ទើរតែពុំមានទេនៅឃុំកាចូន ចំណែកឯប្រជាជនចំណាកស្រុកគឺមានមួយចំនួនប៉ុណ្ណោះ ។

តារាងស្ថិតិជនជាតិដើមភាគតិចដែលរស់នៅក្នុងឃុំកាចូន

| **ជនជាតិដើម ភាគតិច** | **២០០៦** | | **២០០៧** | | **២០០៨** | |
|---|---|---|---|---|---|---|
| | **ចំនួនគ្រួសា** | **ចំនួនប្រជាជន** | **ចំនួនគ្រួសារ** | **ចំនួនប្រជាជន** | **ចំនួនគ្រួសារ** | **ចំនួនប្រជាជន** |
| ទំពួន | ១៧០ | ១.១៤១នា | ១៨៩ | ១.០២៥នាក់ | ២០២ | ៩២២នាក់ |
| គ្រឹង | ៧៨ | ៤៣១នាក់ | ១៥៣ | ៦៨១នាក់ | ៨២ | ៣២៥នាក់ |
| កាវ៉ែត | ៨៤ | ៣៥៥ | - | - | ៣ | ២០នាក់ |
| កាចក់ | ២ | ៤នាក់ | - | - | - | - |
| ព្រៅ | ៧៤ | ៣២៨នាក់ | ៧៤ | ៣២៦នាក់ | ៨៧ | ៤០០នាក់ |

តារាងស្ថិតិជនជាតិផ្សេងៗដែលរស់នៅក្នុងឃុំកាចូន

| **ជនជាតិផ្សេងៗ** | **២០០៦** | | **២០០៧** | | **២០០៨** | |
|---|---|---|---|---|---|---|
| | **ចំនួនគ្រួសារ** | **ចំនួនប្រជាជន** | **ចំនួនគ្រួសារ** | **ចំនួនប្រជាជ** | **ចំនួនគ្រួសា** | **ចំនួនប្រជាជ** |
| ខ្មែរឥស្លាម | - | - | - | - | - | - |
| វៀតណាម | ២ | ៧នាក់ | - | - | ២ | ១២នាក់ |
| ឡាវ | ៦ | ១៣នាក់ | ៣ | ១៩ | ៣ | ២៦នាក់ |

បណ្តាជនជាតិដែលរស់នៅក្នុងឃុំកាចូនមានប្រពៃណីនិងទំនៀមទំលាប់ទៅតាមជនជាតិរបស់គេ ។ជនជាតិទំពួនគ្រឹង កាវ៉ែត កាចក់ ព្រៅ មានព្រពៃណី សាសនាប្រហាក់ប្រហែលគ្នា ដូចជាកាប់ក្របីផឹកស្រា បញ្ជាន់អារក្សជាដើមហើយពួកគេទាំងនោះអាចនិយាយភាសារឆ្លើយឆ្លង គ្នាទៅវិញទៅមកបាន ។ ក្រៅពីនេះមានជនជាតិខ្មែរឡាវ និងវៀតណាមដែលក្នុងនោះជនជាតិឡាវកាន់ប្រពៃណី និងទំនៀមទំលាប់ដូចជាជនជាតិខ្មែរដែរគឺកាន់សាសនាព្រះពុទ្ធ ។

មុខរបរប្រចាំថ្ងៃរបស់ប្រជាជននៅទីនោះគឺកសិកម្មធ្វើស្រែ ចំការ រកផល អនុផលព្រៃឈើ និង បរបាញ់សត្វជាលក្ខណ:គ្រួសារ ឬក៏នេសាទ ។ក្រៅពីនោះពួកគេដាំដំណាំរួមផ្សំ បន្លែបង្ការ ចិញ្ចឹមសត្វ មាន់ ទារ គោ ក្របី ជ្រូក ។ល ។ ស្ថានភាពជីវភាពពុំសូវមានលក្ខណ:ល្អប្រសើរប៉ុន្មានទេដោយសារកើតមានទឹកជំនន់ជារៀងរាល់ឆ្នាំធ្វើអោយខូចខាតផលដំណាំ និងធនធានធម្មជាតិផ្លូវគមនាគមន៍ខូចខាតពិបាកធ្វើដំណើរ ។ នៅក្នុងឃុំកាចូនទាំងមូលក្រៅពីកន្លែងកប់ខ្មោច ព្រៃអារក្សសំរាប់ជនជាតិដើមភាគតិចចេញ នៅមិនទាន់មានវត្តអារាមតាមបែបព្រះពុទ្ធសាសនា និង ព្រះវិហារសំរាប់សាសនាផ្សេងៗទៀតឡើយ ។

ខាងក្រោមនេះគឺជាតារាងបង្ហាញស្ថិតិប្រជាជនគិតតាមអាយុ

| **ស្ថិតិតាមក្រុមអាយុ** | **ប្រុស** | **ស្រី** | **សរុប** | **ផ្សេងៗ** |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ១៤៧ | ១៥៤ | ៣០១ | |
| អាយុ ០៥ឆ្នាំ | ៤៤ | ៦០ | ១០៤ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ១៥១ | ១៤៨ | ២៩៩ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៩៨ | ៨៨ | ១៨៦ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ១១២ | ៩៨ | ២១០ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៩០ | ១០៦ | ១៩៦ | អាយុចូលរៀនមហា |
| អាយុពី ២៥-៦០ឆ្នាំ | ៣៧៩ | ២៩២ | ៦៧១ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៤៧ | ៥៥ | ១០២ | អាយុចូលនិវត្តន៍ |
| **ប្រជាជនសរុប** | **១០៦៨** | **១០០១** | **២០៦៩** | |
| **ចំនួនគ្រួសារសរុប** | **៤៦១** | | | |

**ប្រភព:** ឯកសារពតិមាន ស្តីពីស្ថានភាពឃុំកាចូនឆ្នាំ ២០០៩

### ១.១.៣ ភាពគ្មានដីធ្លី

ប្រជាពលរដ្ឋក្នុងឃុំកាចូនជាទូទៅគឺច្រើនរស់នៅផ្តុំគ្នាជាសហគមន៍ ព្រោះថាមួយភាគធំនៃប្រជាពលរដ្ឋគឺជា ជនជាតិដើមភាគតិចដែលរស់ នៅទីនេះតាំងពីយូរលង់ណាស់ មកហើយ ។ ក្នុងចំណោមប្រជាជន៤៦១គ្រួសារនៅមាន ៦៦គ្រួសារទៀតពុំទាន់មានដីលំនៅដ្ឋានត្រូវជា១៤.៣២%នៃប្រជាជនសរុប ហើយកំណើនប្រជាជនក៏នៅមិនទាន់ខ្ពស់ដែរ ។ចំណែកដីកសិកម្មនៅពុំទាន់គ្រប់គ្រាន់ឆ្លើយតបតំរូវការនៅឡើយទេ កត្តាទាំងនេះគឺបណ្តាលមកពីពួកគេកង្វះលទ្ធភាពក្នុងការប្រើប្រាស់លើដីដែលមាន ពោលគឺការប្រើប្រាស់ ដីនេះពុំមានសមភាពព្រោះគ្រួសារខ្លះមានដីច្រើនលើសលប់ គ្រួសារខ្លះមានដីមិនគ្រប់គ្រាន់ និង គ្រួសារខ្លះពុំមានដីសោះសំរាប់ប្រកបរបរធ្វើស្រែចំការចិញ្ចឹមជីវិត ។ ក្នុងនោះគ្រួសារដែលខ្វះដីកសិកម្មមានចំនួន៨៣គ្រួសារដែលបច្ចុប្បន្នពួកគេធ្វើលើដីស្រែចំការជារបស់អ្នកផ្សេង ឬក៏ ស៊ីឈ្នួលគេដូចជា បេះគ្រាប់ចន្ទី ជំរះស្មៅ សណ្តែកសៀង រកអនុផលព្រៃឈើ អាឈើលក់ និងនេសាទត្រី ។ រីឯ៩២គ្រួសារទៀតមានដីមិនដល់១ហិចតាទេ គួបផ្សំជាមួយទិន្នផលស្រូវទាបផងនោះជាហេតុធ្វើអោយជីវភាពពួកគេ មានកំរិតទាបយ៉ាងខ្លាំង ។

តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់

| **លរ** | **បរិយាយ** | **ចំនួនគ្រួសារ** | **ភាគរយ/ប្រជ.សរុប** | **ផ្សេងៗ** |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ៨៣ | ១៨,៤០% | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ៩២ | ២០,៤០% | |
| ៣ | គ្មានដីលំនៅដ្ឋាន | ៦៦ | ១៤.៣២% | |

**ប្រភព:** របាយការណ៍ ស្តីពីស្ថានភាពឃុំកាចូន ឆ្នាំ ២០០៩



**រូបភាព២:** គ្រួសារគ្មានដីលំនៅដ្ឋាន

## ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋមួយភាគធំនៅឃុំកាចូនប្រកបមុខរបរធ្វើស្រែ ចំការ ក្រៅពីការងារស្រែ ចំការ ពួកគេមានមុខរបរបន្ទាប់បន្សំមួយចំនួនទៀតដូចជា នេសាទត្រី បរបាញ់សត្វ ធ្វើសួនបន្លែតាមលក្ខណៈគ្រួសារដូចជា ដាំពោត សណ្តែក ចេក ល្ង ដំឡូង អំពៅ ដំណាំហូបផ្លែ និងបន្លែបង្ការផ្សេងៗជាច្រើនមុខទៀត។ ផលិតផលដែលបានមកពួកគាត់ ប្រើប្រាស់សំរាប់តំរូវការប្រចាំថ្ងៃ និងមួយចំនួនទៀតសំរាប់លក់ដូរដើម្បីទិញសំភារៈប្រើប្រាស់ផ្សេងៗ។ ក្រៅពីនេះពួក គេទទួលបានចំណូលមកអំពីការស៊ីឈ្នួលគេ និងអំពីការលក់សត្វក្នុងស្រុកដូចជា គោ ក្របី ជ្រូក មាន់ទា ។ល។ ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំនេះ ពុំសូវមានលក្ខណៈល្អប្រសើរប៉ុន្មានទេ ដោយសារតំបន់នេះជួបគ្រោះធម្មជាតិជារៀងរាល់ឆ្នាំដូចជាព្យុះ ទឹកជំនន់ ធ្វើអោយខូចទិន្នផលស្រែចំការ បណ្តាលអោយពួកគាត់ខ្វះខាតស្បៀងសំរាប់ចិញ្ចឹមជីវិត។ ចំណែកផ្លូវគមនាគមន៏ក៏ជួបការលំបាកក្នុងការធ្វើដំណើរ ចំពោះប្រជាពលរដ្ឋដែលមានភូមិនៅឆ្ងាយ។

<u>តារាងមុខរបរសំខាន់ៗរបស់ប្រជាជនឃុំកាចូន</u>

| **ល.រ** | **ប្រភេទមុខរបរ** | **ចំនួនគ្រួសារ** | | **ផ្សេងៗ** |
|---|---|---|---|---|
| | | **ចំនួន** | **ភាគរយ (%)** | |
| ១ | មុរបរកសិកម្ម | | | |
| | ធ្វើស្រែជាចំបង | ៤៥១ | ៩៧,៨៣ | ស្រែវស្សា និង ស្រែប្រាំង |
| | ដាំដំណាំរយៈពេលវែងជាចំបង | 0 | 0 | |

| | | | | |
|---|---|---|---|---|
| | ដាំដំណាំរយៈពេលខ្លីជាចំបង | ១០ | ២,១៧ | ពោត ,សណ្តែកដី,ឪឡឹក..... |
| | ដាំដំណាំបន្លែជាចំបង | 0 | 0 | |

**ប្រភព:** របាយការណ៍ ស្តីពីស្ថានភាពឃុំកាចូន ឆ្នាំ ២០០៩

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

លើវិស័យអប់រំ ឃុំកាចូនមានអត្រានៃការសិក្សានៅទាបនៅឡើយ តាមការពិនិត្យជាក់ស្តែងឃើញថាចំនួនកុមារថ្នាក់មត្តេយ្យមានចំនួន ១០៤នាក់ តែពុំមានសាលារៀននោះទេ ។កំរិតបឋមសិក្សាមានសាលាចំនួន៥ខ្នងបន្ទប់ចំនួន១១ ថ្នាក់ចំនួន១២ មានសិស្សសរុប១៦០នាក់និងគ្រូ៦នាក់ប៉ុណ្ណោះ ។នៅកំរិតបឋមសិក្សានេះឃើញមានដំណើរការល្អគ្រាន់បើតែចំនួនសិស្សចូលរៀនមានតិចជាង ច្រើនធៀបនឹងចំនួនសិស្សសរុបបញ្ហានេះបណ្តាលមកពីកំរិតជីវភាពរបស់ពួកគេពុំអាចដោះស្រាយតាមតំរូវការសំរាប់ការសិក្សារបស់កូនបាន ។ចំណែកសាលាអនុវិទ្យាល័យមានការចុះទាបកាន់តែខ្លាំងដោយសារមានតែចំនួនសិស្ស ឯគ្រូបង្រៀនគឺពុំមានព្រោះជាតំបន់ជនបទដាច់ស្រយាលគ្រូភាគច្រើន មាននៅតែបានលុងទីរួមខេត្ត ។

- ចំនួនមត្តេយ្យ:....0....ចំនួនថ្នាក់/បន្ទប់:....0...ចំនួនសិស្ស:...0...ចំនួនគ្រូ...0..
- ចំនួនសាលាបឋមសិក្សា:..០៥..ចំនួនថ្នាក់..១២..បន្ទប់:.១១..ចំនួសិស្ស:.១៦០ ចំនួនគ្រូ.០៦
- ចំនួនអនុវិទ្យាល័យ:..0.ចំនួនថ្នាក់.0..បន្ទប់:..0.ចំនួសិស្ស:..៩៧.ចំនួនគ្រូ..0
- ចំនួនវិទ្យាល័យ:.0..ចំនួនថ្នាក់/បន្ទប់:......0...ចំនួសិស្ស:.....១០០.....ចំនួនគ្រូ....0......
- ចំនួនសាលាអក្ខរកម្ម:..0..ចំនួនថ្នាក់/បន្ទប់:..0...ចំនួសិស្ស:...១០៧៤..ចំនួនគ្រូ.....០២

<u>តារាងស្ថិតិសាលា និងចំនួនសិស្សប្រចាំឆ្នាំ ២០០៨</u>

| **ប្រភេទសាលា** | **ចំនួនសាលានៅឆ្នាំ ២០០៨** | | | **ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨** | | | **អត្រាមិនចូលរៀន** |
|---|---|---|---|---|---|---|---|
| | **សាលា** | **បន្ទប់** | **ថ្នាក់** | **កុមារសរុប** | **សិស្សសរុប** | **សិស្សស្រី** | |
| ថ្នាក់មត្តេយសិក្សា | 0 | 0 | 0 | ១០៤ | 0 | 0 | ១០០% |
| ថ្នាក់បឋមសិក្សា | ០៥ | ១១ | ១២ | ២៩៩ | ១៦០ | ៨០ | ២៨,០៥% |
| ថ្នាក់អនុវិទ្យាល័យ | 0 | 0 | 0 | ១៨៦ | ៩៧ | ៥១ | ៤៧,៨៥% |
| ថ្នាក់វិទ្យាល័យ | 0 | 0 | 0 | ២១០ | ១០០ | - | ៥២,៣៨% |

**ប្រភព:** ឯកសារពតិមាន ស្តីពីស្ថានភាពឃុំកាចូន ឆ្នាំ ២០០៩



**រូបភាព៣:** សាលាបឋមសិក្សាឃុំកាចូន

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

ឃុំកាចូនមានឆ្មបបុរាណចំនួន ២៧នាក់ក្នុងនោះ ០៨នាក់ បានបណ្តុះបណ្តាលរួច ដោយអង្គការ H.U ហើយកំពុងដំណើរការនៅក្នុងឃុំ ។ឃុំនេះជួបប្រទះជំងឺកាចសាហាវតែងតែយាយីប្រជាពលរដ្ឋជាញឹកញាប់រួមមានៈ ជំងឺផ្លូវ ដង្ហើម ជំងឺរាគ ជំងឺគ្រុនចាញ់ ជំងឺភ្នែក....។ ស្ត្រីភាគច្រើនមានចំណេះដឹងទាប រស់នៅតំបន់ដាច់ស្រយាល ជឿលើទំនាម ទំលាប់ ប្រពៃណីជាធំគួបផ្សំនឹងផ្លូវគមនាគមន៏ពិបាកខ្លាំងផងធ្វើអោយពួកគេមិនអាចមកទទួលសេវាសុខភាពពីមណ្ឌលសុខភាព បានដែលជាហេតុបណ្តាលអោយស្ត្រីទទួលរងគ្រោះថ្នាក់និងស្លាប់កុមារ។ អត្រាស្លាប់របស់កុមារអាយុក្រោម ៥ឆ្នាំ មានប្រហែល ៣៤%។

ស្ត្រីនិងកុមារត្រូវបានថែរក្សារនិងគាំពារដោយការចាក់ថ្នាំបង្ការជារៀងរាល់ខែនៅតាមភូមិរដ្ឋបាលនិងភូមិបំបែកដែលក្នុងនោះរួមមាន ការចាក់ថ្នាំបង្ការជំងឺតេតាណូសទៅលើស្ត្រីក្នុងវ័យបន្តពូជពីអាយុ ១៥-៤៤ឆ្នាំ ចំនួន ៥ដង ក្នុងគោលបំណងអោយម្តាយជៀសផុតពីជំងឺស្កន់ និងកុមារជៀសផុតពីជំងឺតេតាណូសផ្ចិត។

កុមារភាគច្រើននៅក្នុងឃុំត្រូវបានសង្គ្រោះដោយការផ្តល់កម្មវិធីអាហារូបត្ថម្ភដល់កុមារដែលកង្វះជីវជាតិ ហើយកុមារទទួលបានជីវជាតិគ្រប់គ្រាន់នូវអាហារបីប្រភេទ និងមានសុខភាពល្អលូតលាស់ត្រឹមត្រូវអាចទប់ទល់នឹងជំងឺទាំងឡាយ។ ស្ថានភាពនៃការបញ្ជូនអ្នកជំងឺពីភូមិ ឬ ឃុំមួយចំនួនទៅកាន់មណ្ឌលសុខភាព រឺមន្ទីរពេទ្យបង្អែកខេត្តជួប ប្រទះការលំបាកជាច្រើនដោយហេតុថា :

- ផ្លូវពីភូមិ ឬឃុំទៅទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកមានសភាពទ្រុឌទ្រោម

- ប្រជាពលរដ្ឋភាគច្រើនពុំមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬមានចំនួនតិចតួច ហើយមានសភាពទ្រុឌទ្រោម ចំណែកឯមណ្ឌលសុខភាពឃុំ ពុំទាន់មានមធ្យោបាយដឹកជញ្ជូនអ្នកជំងឺឡើយ ។

- មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកខេត្តទទួលខុសត្រូវលើសេវាដឹកជញ្ជូនតែអ្នកជំងឺដែលមានលំនៅក្នុងខេត្ត រីឯមន្ទីរពេទ្យបង្អែកគ្របដណ្តប់តំបន់ក្រៅពីនោះសេវាដឹកជញ្ជូនជាបន្ទុករបស់អ្នកជំងឺ រឺក៏អង្គការផ្សេងៗ ។

តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ

| ល.រ | មណ្ឌល/ប៉ុស្តិសុខភាព | សមត្ថភាពផ្តត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ១ | ១ | ៥ | - | ២៧ |
| ២ | ប៉ុស្តិសុខភាពភូមិ | 0 | 0 | 0 | 0 | 0 |

**ប្រភព:** របាយការណ៍ ទទួលបានពីមន្ទីរសុខាភិបាលខេត្ត ឆ្នាំ ២00៩




***រូបភាព៤:*** មណ្ឌលសុខភាពឃុំកាចូន

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ប្រជាពលរដ្ឋភាគច្រើនក្នុងឃុំកាចូនប្រើប្រាស់ទឹកពីអូរ ច្រប់ (ជាកន្លុកទឹកធម្មជាតិ មានប្រភពមកពីភ្នំ) អណ្តូងស្នប់ អណ្តូងលូ និងអណ្តូងដៃ ។ល ។ ប៉ុន្តែប្រភពនៃការផ្គត់ផ្គង់ទឹកស្អាតពុំទាន់គ្រប់គ្រាន់ តាមសេចក្តី ត្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋឃុំកាចូននៅឡើយទេ ព្រោះចំនួនអណ្តូងទឹកស្អាតមានចំនួនទាំងអស់២៩ គឺប្រើការបាន

តែ២៣អណ្តូងប៉ុណ្ណោះចំណែក៦អណ្តូងទៀតរីងរាក់ និងមិនអាចប្រើការបាននៅរដូវប្រាំងហើយ អណ្តូងមួយចំនួនទៀតស្ថិត នៅឆ្ងាយពីប្រភពទឹក មិនអាចរក្សាទឹកទុកប្រើប្រាស់បានយូរ ។

ចំពោះអណ្តូងស្នប់ដែលបានខូចត្រូវបានទុកចោលយូរមិនបានជួសជុលហើយរហូតមកដល់ពេលនេះស្ទើរតែមិនអាចជួសជុលបានទាំងស្រុង។ ដោយឡែកចំពោះអណ្តូងលូ និងអណ្តូងដៃមួយចំនួនគ្មានទឹក ឬបើសិនជាមានទឹកក៏ទឹកនោះក៏មិនអាចប្រើប្រាស់បានព្រោះទឹកល្អក់ហើយមានពណ៌លឿង ។ដូច្នេះអណ្តូងទឹកដែលខូចទាំងអស់ត្រូវស្តារឡើងវិញទាំងស្រុងដើម្បីអាចទទួលបានទឹកស្អាតប្រើប្រាស់ ។

តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំកាចូន

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ | ២ | ១ | ១ | ខូចត្រូវជួសជុលឡើងវិញ |
| ២ | អណ្តូងលូ( បានដាក់លូ) | ៣ | ០ | ៣ | ខូចត្រូវស្តារឡើងវិញ |
| ៣ | អណ្តូងដៃ( មិនបានដាក់លូ) | ២៤ | ២២ | ២ | ខូចត្រូវស្តារឡើងវិញ |

ប្រភព: ឯកសារពតិមាន ស្តីពីស្ថានភាពឃុំកាចូន ឆ្នាំ ២០០៩



**រូបភាព៣៥:** អណ្តូងដៃនៅក្នុងឃុំកាចូន

# ១.២ ស្ថានភាពភូមិសាស្ត្រ

## ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំកាចូនមានរាងទ្រវែងបណ្តោយប្រមាណជា ១៥.៤០គម និងទទឹងប្រមាណជា ៦.៤៣គម លាតសន្ធឹងពីទិសពាយ័ព្យមកទិសអគ្នេយ៏ មានសណ្ឋានដីខ្ពស់-ទាប ផ្នែកខាងជើងនៃឃុំស្ថិតនៅជាប់នឹងដងទន្លេសេសាន។

ផ្នែកខាងជើងដែលជាប់នឹងទន្លេមានរយៈកំពស់ពី៨២មដល់១៣៨ម រហូតស្ទើរតែមកដល់ពាក់កណ្តាលនៃឃុំបន្តមកខាងត្បូងមានរយៈកំពស់ពី ១៣៨ម ដល់ ២១៦ម ហើយភាគខាងត្បូងជាតំបន់កូនភ្នំដែលអាចមានរយៈកំពស់ពី ២១៦ម រហូតដល់ ៤០២ម។




***រូបភាព១៦:*** ផែនទីបង្ហាញរយៈកំពស់

## ១.២.២ អាកាសធាតុ

យោងតាមប្រភពទិន្នន័យពីនាយកដ្ឋានឧត្តុនិយម និងជលសាស្ត្រនៃក្រសួងធនធានទឹក និងឧត្តុនិយមកម្ពុជាពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៦ បានអោយដឹងថាខេត្តរតនគីរីមានកំពស់ទឹកភ្លៀងជាអតិបរិមា២៧៩១.៧ មម គឺនៅឆ្នាំ២០០៦ និងកំពស់ទឹកភ្លៀងអប្បរមាមាន ២១១៩.៨មម គឺនៅឆ្នាំ ២០០៤ប៉ុន្តែជាទូទៅកំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំក្នុងអំឡុងពេលនៃកំណត់ត្រាខាងលើមាន២៤៤០.៨៥មម ។ដោយឡែកកំពស់ទឹកភ្លៀងប្រចាំឆ្នាំ ២០០៩ នៃស្ថានីយ៍នៅ ក្នុងឃុំកាចូន/ស្រុកវើនសៃមានត្រឹមតែ២៩០.២០មមប៉ុណ្ណោះ។

រដូវនៅក្នុងខេត្តមាន២រដូវគឺរដូវប្រាំងនិងរដូវវស្សា រយៈពេលនៃរដូវប្រាំងមានរយៈពេល៦ខែ គឺរាប់ចាប់ពីខែ វិច្ឆិកា ដល់ខែ មេសា និងរយៈពេលនៃរដូវវស្សាមានរយៈពេល ៦ខែ គឺពីខែឧសភាដល់ខែ តុលា សំរាប់ខេត្តរតនគីរីតែនិយាយចំពោះឃុំកាចូន គឺមានភ្លៀងធ្លាក់ចាប់ពីខែឧសភារហូតដល់ខែវិច្ឆិកាជារៀងរាល់ឆ្នាំគឺមានរយៈពេល៧ខែ។

- សីតុណ្ហភាពអតិបរមាពី ៣៤.៧អង្សាសេ ដល់ ៣៨.៨.អង្សាសេ និងអប្បរមាពី ១៨.៥អង្សាសេ ទៅ ២១.៥ អង្សាសេ និយាយជារួមសំរាប់ខេត្តរតនគីរី ចំពោះឃុំកាចូនអាចត្រជាក់ជាងនេះព្រោះជាតំបន់គ្របដណ្តប់ដោយព្រៃឈើ ហើយស្ថិតនៅជាប់នឹងដងទន្លេ។




| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| " 2003" | 0.0 | 0.0 | 90.8 | 121.0 | 390.2 | 287.1 | 480.3 | 396.6 | 452.7 | 77.6 | 55.6 | 0.0 |
| " 2004" | 0.0 | 0.0 | 48.6 | 23.8 | 172.0 | 511.1 | 413.8 | 509.4 | 400.5 | 32.6 | 8.0 | 0.0 |
| "2005" | 0.0 | 0.0 | 6.4 | 48.8 | 195.7 | 300.9 | 643.6 | 746.7 | 408.5 | 128.4 | 13.6 | 7.4 |
| " 2006" | 0.0 | 0.0 | 0.0 | 147.2 | 317.6 | 212.2 | 682.9 | 642.0 | 504.5 | 257.6 | 0.0 | 27.7 |

## ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

(មើលតាមផែនទីប្រើប្រាស់ដីលំអិតដែលបានធ្វើបច្ចុប្បន្នភាពរួចជាមួយក្រុមប្រឹក្សាឃុំ...)

- **ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**

**ផ្លូវគោក:** ឃុំកាចូនមានផ្លូវគ្រួសក្រហមចំនួន២ខ្សែ គឺ១ខ្សែស្ថិតតាមបណ្តោយដងទន្លេរហូតមកដល់ផ្លូវបំបែក ទៅឃុំកាចូន និង១ខ្សែទៀតពីផ្លូវបំបែកកាត់តាមសាលាឃុំកាចូនមកជួបផ្លូវភ្ជាប់ពីបានលុងទៅដល់សាលាស្រុកវើនសៃមានប្រវែងសរុប១៨,៥៥៥គម ។ក្រៅពីនោះផ្លូវមួយភាគធំជាផ្លូវថ្មើរជើងសំរាប់ប្រជាពលរដ្ឋធ្វើដំណើររកផលឬអនុផលព្រៃឈើដែលមានប្រវែងសរុប៤០,០៧៧គម ។នៅលើបណ្តាផ្លូវដែលប្រើប្រាស់ទាំងនោះយើងមានស្ពានឈើចំនួន៦ស្ពាននិងលូឆ្លងផ្លូវចំនួន៥ ។

**ផ្លូវទឹក:**ក្រៅពីផ្លូវគោកឃុំមានទន្លេសេសានដែលអាចអោយប្រជាពលរដ្ឋធ្វើដំណើរភ្ជាប់ពីឃុំទៅឃុំពីស្រុកទៅស្រុកនិងអាចធ្វើដំណើរឆ្លងខេត្តផងដែរព្រោះទន្លេសេសាននេះភ្ជាប់ទៅនឹងទន្លេដែលស្ថិតនៅក្នុងស្រុកសៀមប៉ាងខេត្តស្ទឹងត្រែងផងដែរ ។ មធ្យោបាយគឺគេប្រើប្រាស់កាណូត និងទូកម៉ាស៊ីនជាមធ្យោបាយដឹកជញ្ជូនទំនិញ ដឹកអ្នកដំណើរ ។



**រូបភាព៧:** ផ្លូវថ្មីកំពុងឈូសឆាយ



**រូបភាព៨:**ផ្លូវគ្រួសក្រហមដែលបានសាងសង់រួច

- **ប្រព័ន្ធស្រោចស្រព**

ប្រព័ន្ធស្រោចស្រពដែលមាននៅឃុំកាចូនបច្ចុប្បន្នពុំបានដាក់បញ្ចូលទៅក្នុងផែនទីទេ ក្នុងនោះរួមមាន ប្រឡាយមេ១ខ្សែប្រវែង១,៥គម ប្រឡាយរង១ខ្សែប្រវែង០,៩គម និងទ្វារទឹកចំនួន១២ ដោយមូលហេតុប្រជាពលរដ្ឋនៅក្នុងឃុំ ពុំមានថវិកាគ្រប់គ្រាន់សំរាប់ចំណាយលើការទិញម៉ាស៊ីនភ្លើង និងទិញប្រេងដើម្បីបូមទឹកពីទន្លេចូលទៅ ប្រព័ន្ធស្រោច ស្រពទាំងនេះ ព្រោះថាប្រភពផ្តល់ទឹកគឺយកចេញពីទន្លេសេសានដែលមានកំពស់ទាបជាងដីដែលត្រូវស្រោចស្រព។

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅឃុំកាចូនមានចំនួន១២ប្រភេទខុសៗគ្នាដែលក្នុងនោះរួមមានដីលំនៅដ្ឋានភូមិ( ផ្ទះ-ឈើហូបផ្លែ) ស្រែស្រូវវស្សា( ស្រូវវស្សា) ដីកសិកម្មពនេចរ (ដីដូរវេនដំណាំ-ចំការផ្លាស់វេនដំណាំ) ព្រៃស្រោងសើម ( ព្រៃញ៉ាតមានឈើធំៗ) ព្រៃល្បោះ ព្រៃចំរុះ( ស្រោង និងរបោះ) ព្រៃដុះឡើងវិញ ( ព្រៃកម្ពោធ ) ចំការបោះបង់ដុះស្មៅ ( ព្រៃបូស) ព្រៃគម្ពោធ ចំការបោះបង់ដុះព្រៃគម្ពោធ ដីខ្សាច់ អូរ-ទន្លេ ។

<u>តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត</u>

| **លរ** | **ប្រភេទនៃការប្រើប្រាស់ដី** | **ទំហំ (ហត)** | | **ចំណាត់ថ្នាក់របស់មូលដ្ឋាន** |
|---|---|---|---|---|
| | | **$ម^2$** | **ហត** | |
| ១ | ដីលំនៅដ្ឋានភូមិ | ៩២១៨៤ | ៩ | ផ្ទះ-ឈើហូបផ្លែ |
| ២ | ស្រូវវស្សា | ៣៣៤៧៦១០ | ៣៣៥ | ស្រូវវស្សា |
| ៣ | ដីកសិកម្មពនេចរ | ៩៥៨០៨៨១ | ៩៥៨ | ដីចំការផ្លាស់វេន |
| ៤ | ព្រៃស្រោងសើម | ២៣៦២៤១៤៧ | ២៣៦២ | ព្រៃញ៉ាតមានឈើធំៗ |
| ៥ | ព្រៃរបោះ | ៥៣៦៣៣៤៧ | ៥៣៦ | ព្រៃល្បោះ |
| ៦ | ព្រៃចំរុះ( ស្រោង និងរបោះ) | ៨០៨១៩៧៦ | ៨០៨ | ព្រៃចំរុះ ( ស្រោង និងរបោះ) |
| ៧ | ព្រៃដុះឡើងវិញ | ១៥៣៦៦៦៣៦ | ១៥៣៧ | ព្រៃកម្ពោធ |
| ៨ | ចំការបោះបង់ដុះស្មៅ | ២២៦៩០១២ | ២២៧ | ព្រៃបូស |
| ៩ | ព្រៃគម្ពោធ | ២៦៤៧២២៩ | ២៦៥ | ព្រៃគម្ពោធ |
| ១០ | ចំការបោះបង់ដុះព្រៃគម្ពោធ | ៧៤៩១៥៣៥ | ៧៤៩ | ចំការបោះបង់ដុះព្រៃគម្ពោធ |
| ១១ | ដីខ្សាច់ | ២២៣៩៩២ | ២២ | ដីខ្សាច់ |
| ១២ | អូរ-ទន្លេ | ២៦៧៩៦៨៩ | ២៦៨ | អូរ-ទន្លេ |
| **សរុប** | | **៨០៧៦៨៥០៩** | **៨០៧៦** | |

<u>ប្រភព</u>: ទិន្នន័យភូមិសាស្ត្របានធ្វើបច្ចុប្បន្នភាពជាមួយក្រុមប្រឹក្សាឃុំ ថ្ងៃ០៣ ខែមិថុនា ឆ្នាំ២០០៩

### ១.៣.២ ស្ថានភាពនៃការគ្រប់គ្រងនិងកាន់កាប់ដី

ដីក្នុងឃុំកាចូនទាំងមូលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ និងកាន់កាប់ដោយផ្ទាល់ភាគច្រើនជារបស់ប្រជាពលរដ្ឋ ដែលជាម្ចាស់កម្មសិទ្ធិដី។ ដីស្ទើរតែទាំងអស់ពុំទាន់មានការចុះបញ្ជី និង ចេញប័ណ្ណសំគាល់អចលនវត្ថុ ជូនដល់ប្រជាពលរដ្ឋនៅឡើយទេ ឯចំពោះដីកសិកម្មចំការពនេចរ គឺពួកគាត់មានការគ្រប់គ្រង និងកាន់កាប់តាមបែប ប្រពៃណី។ការទិញ លក់ដី កើតមានតិចតួច ដោយសារមានអ្នកចំណូលថ្មីចូលទៅតាំងទីលំនៅក្នុងឃុំនោះ។ និយាយរួមក្រៅពីដីលំនៅដ្ឋាន ស្ទើរតែទាំងអស់នៃផ្ទៃដីគឺជាដីសាធារណៈរបស់រដ្ឋ ដូចជាៈ

- ព្រៃសហគមន៍អណ្តូងព្រះនាងមានផ្ទៃដីសរុបប្រហែល ១,៤០៨ហិចតា ជាតំបន់សំបូរដោយឈើប្រណិត។ និងសំបូរទៅដោយជីវៈចំរុះច្រើនប្រភេទ និងមានប្រភេទព្រៃដូចជាៈចំការបោះបង់ដុះស្មៅ ចំការបោះបង់ដុះព្រៃគម្ពោធ ព្រៃស្រោងសើម ព្រៃចំរុះ(ស្រោងនិងរបោះ) ព្រៃដុះឡើងវិញនិងព្រៃគម្ពោធដែលកន្លងមកត្រូវបានប៉ុនប៉ងចូលរុករាន ទន្ទ្រានពីជនខិលខូច ។
- ជាតំបន់ស្ថិតនៅជាប់ដងទន្លេសេសានជាតំបន់សំបូរដោយធនធានមច្ឆាចំរុះច្រើនប្រភេទ តំរូវអោយមានកិច្ចការពារជាពិសេសដើម្បីធានានូវភាពគង់វង្សនៃពពួកពូជត្រីនៅក្នុងតំបន់នោះ។

<u>តារាងសង្ខេបស្ថានភាពកាន់កាប់និងគ្រប់គ្រងដី</u>

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហត) | ផ្សេង។ |
|---|---|---|---|
| ១ | ព្រៃសហគមន៍អណ្តូងព្រះនាង | ១.៤០៨ | ដីសាធារណៈរបស់រដ្ឋ |
| | ចំការបោះបង់ដុះស្មៅ | ២០ | ១កន្លែង |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | ១៣៨ | ១កន្លែង |
| | ព្រៃស្រោងសើម | ៣៦៤ | ១កន្លែង |
| | ព្រៃចំរុះ(ស្រោងនិងរបោះ) | ៣៨៤ | ១កន្លែង |
| | ព្រៃដុះឡើងវិញ | ៤៨១ | ១កន្លែង |
| | ព្រៃគម្ពោធ | ២១ | ១កន្លែង |
| ២ | ផ្នែកនៃទន្លេសេសាន | ផ្ទៃទឹក | សាធារណៈរបស់រដ្ឋ |

**<u>ប្រភព</u>**ៈ ខណ្ឌរដ្ឋបាលព្រៃឈើរតនគីរី

### ១.៣.៣ ស្ថានភាពកសិកម្ម

ប្រជាជនទូទាំងឃុំកាចូនទាំងមូលសុទ្ធតែប្រកបរបរកសិកម្ម ក្នុងនោះចំនួនគ្រួសារធ្វើស្រែ៩៧,៨៣% និង ២,១៧% ធ្វើចំការដាំដំណាំរយៈពេលខ្លី ។ តំបន់នេះជាតំបន់ដែលដីពុំសូវមានជីជាតិ ទិន្នផលស្រូវមានកំរិតទាបពោលគឺ ក្នុងមួយហិចតាដីផ្តល់ផលស្រូវវស្សាបានតែ ១,០តោន ឯស្រូវប្រាំងវិញគឺបានតែ ០.៥០តោនប៉ុណ្ណោះ។ ក្រៅពីនោះ ពួកគេដាំដំណាំចំការដែលផ្តល់ផលបានច្រើនតែនៅឆ្នាំទីមួយ ចំណែកឆ្នាំបន្ទាប់ៗទៀតគឺពុំសូវបាន

ផលទេ ហើយដីនេះ ត្រូវបានគេទុកចោលអស់រយៈពេលច្រើនឆ្នាំរហូតដល់ទៅពី៥ដល់៧[១] ឆ្នាំ ទើបវិលត្រលប់មកដាំដំណាំសារជាថ្មីម្តងទៀត លើដីនោះវិញ ។ចំណែកមធ្យោបាយអូសទាញនៅទូទាំងឃុំមានគោយន្តតែ ០៧គ្រឿង ក្រៅអំពីនេះគឺពួកគាត់ប្រើប្រាស់ គោ-ក្របីជាកំលាំងអូសទាញសំរាប់ការងារស្រែ ចំការ ។

ប្រជាជនទូទាំងឃុំកាចូនទាំងមូលសុទ្ធតែប្រកបរបរកសិកម្ម ក្នុងនោះចំនួនគ្រួសារ ធ្វើស្រែ៩៧,៨៣% និង ២,១៧% ធ្វើចំការដាំដំណាំរយៈពេលខ្លី ។ តំបន់នេះជាតំបន់ដែលដីពុំសូវមានជីជាតិ ទិន្នផលស្រូវមានកំរិតទាបពោលគឺ ក្នុងមួយហិកតាដីផ្តល់ផលស្រូវវស្សាបានតែ ១,០តោន ឯស្រូវប្រាំងវិញគឺបានតែ ០.៥០តោនប៉ុណ្ណោះ ។ ក្រៅពីនោះ ពួកគេដាំដំណាំចំការដែលផ្តល់ផលបានច្រើនតែនៅឆ្នាំទីមួយ ចំណែកឆ្នាំបន្ទាប់ៗទៀតគឺពុំសូវបានផលទេ ហើយដីនេះ ត្រូវបានទុកចោលអស់ពេលយ៉ាងយូររហូតដល់ទៅពី៥ដល់៧ឆ្នាំទើបវិលត្រលប់មកដាំដំណាំសារជាថ្មីលើដីនោះ។ ចំណែកមធ្យោបាយអូសទាញនៅទូទាំងឃុំមានគោយន្តតែ ០៧គ្រឿង ក្រៅអំពីនេះគឺពួកគាត់ប្រើប្រាស់គោ-ក្របីជាកំលាំងអូសទាញសំរាប់ការងារស្រែ ចំការ ។



**រូបភាព៩ :** កសិកម្មពនេចរសំរាប់ដំណាំស្រូវ

**<u>តារាងប្រភេទដំណាំកសិកម្មសំខាន់ៗ និងទិន្នផលទទួលបាន</u>**

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី (ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប(ហត) | ដាំបាន (ហត) | ផលសរុប(តោន) | ទិន្នផល(ត/ហត) |
| ១ | ដំណាំស្រូវវស្សា | ២៨៧ | ២៧៧ | ២៧៧ | ១ |
| ២ | ដំណាំស្រូវចំការ | ៩៣ | ៩៣ | ៤៦.៥០ | ០.៥ |

[១] ខួបរយៈពេល ៧ឆ្នាំសំរាប់កសិកម្មពនេចរ គឺជាខួបមួយខ្លី ដែលការវិលជុំបែបនេះនឹងធ្វើឱ្យដីខ្សោះជីជាតិជាលំដាប់

ប្រភព: ឯកសារពតិមាន ស្តីពីស្ថានភាពឃុំកាចូន ឆ្នាំ ២០០៩ ( ទិន្នផលស្រូវមធ្យម០១ឆ្នាំចុងក្រោយ: ...ត/ហត)

## តារាងក្រឡាផ្ទៃតាមផលិតភាពដី ការប្រើប្រាស់ និងផលិតផល

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា ហិចតា |
|---|---|---|---|
| ១ | **ដីមានផលិតភាពទាប** | ល្បាយខ្សាច់ - ល្បាយគ្រួស | |
| | ចំការបោះបង់ដុះស្មៅ | ស្មៅ ស្បូវ បន្លាអូរយ៉ាក់ ល្វៀង... | ២៧ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | មានព្រៃគុម្ពោធៈដើមកូនសុក្រំ កូនកកោះ កូនស្រឡៅ កូនចំបក់.... | ៣៣២ |
| | ព្រៃរបោះ | មានដើមត្រាច ខ្លុង ពពេល ផ្ចឹក... | ៥០ |
| | ព្រៃស្រោងសើម | បេង នាងនួន កកោះ ស្រឡៅ ក្រញូង ឈើទាល សុក្រំ គគីរ សាខារ... | ២២២៨ |
| | ព្រៃចំរុះ( ស្រោង និង របោះ) | មានឈើត្រាច ផ្ចឹក ខ្លុង ពពេល បេង នាងនួន កកោះ ស្រឡៅ ក្រញូង ទាល សុក្រំ គគីរ ។ល។ | ៦៤១ |
| | ព្រៃដុះឡើងវិញ | មានដើមសុក្រំ កកោះ ស្រឡៅ ចំបក់ ពពេល ផ្ទៀក ផ្តក... | ៩៧២ |
| | ព្រៃគម្ពោធ | ចុល្លព្រឹកក្រាស់ វាលស្មៅ និងដើមឈើមួយចំនួនទៀត ដែលអាចក្លាយទៅជាឈើធំៗប្រសិនបើយើងមិនកាប់វា | ២០៤ |
| | ដីកសិកម្មពនេចរ | ភាគច្រើនដាំចេក,អំពៅ,ដំឡូង, ពោត,សណ្តែក,ស្ពៃ. សាឡាត់... | ៩៤១ |
| | ស្រូវវស្សា | - សំរាប់ស្រូវធ្ងន់ :នាងនូ,ក្រមួនស សូមាលី<br>- ស្រូវស្រាល : នាងខួន ក្រចកចាប ប្រវិកស<br>- ស្រូវកណ្តាល :ស្រូវដំណើប ចំបើងលឿង ប្រកិន ផ្កាខ្ញី | ១០១ |
| ២ | ដីមានផលិតភាពខ្ពស់ | ល្បាយឥដ្ឋ-កណ្តេងប្រផេះល្បាប់អាចម៏កណ្តុរ | |
| | ដីខ្សាច់ ( គួរពិនិត្យឡើងវិញ) | ដីខ្សាច់ | ២១ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | មានដើមសុក្រំ កកោះ ស្រឡៅ ចំបក់ ពពេល ផ្ទៀក ផ្តក... | ៩០៤ |
| | ចំការបោះបង់ដុះស្មៅ | ស្មៅ ស្បូវ បន្លាអូរយ៉ាក់ ល្វៀង... | ២០០ |
| | ព្រៃស្រោងសើម | បេង នាងនួន កកោះ ស្រឡៅ ក្រញូង ឈើទាល សុក្រំ គគីរ សាខារ ។ល ។ | ១៣៤ |
| | ព្រៃចំរុះ( ស្រោង និង របោះ) | រួមមានឈើត្រាច ផ្ចឹក ខ្លុង ពពេល បេង នាងនួន កកោះ ស្រឡៅ ក្រញូង ទាល សុក្រំ គគីរ ។ល។ | ១៦៧ |
| | ទន្លេ ស្ទឹង អូរ | ខ្សាច់ ធនធានមច្ឆា ជាប្រព័ន្ធស្រោចស្រពដល់ដីស្រែ ដីចំការ និងការពារជីវៈចំរុះ | ២៦៨ |
| | ព្រៃដុះឡើងវិញ | មានដើមសុក្រំ កកោះ ស្រឡៅ ចំបក់ ពពេល ផ្ទៀក ផ្តក... | ៥៦៣ |
| | ព្រៃគម្ពោធ | ចុល្លព្រឹកក្រាស់ វាលស្មៅ និងដើមឈើមួយចំនួនទៀត ដែលអាចក្លាយទៅជាឈើធំៗប្រសិនបើយើងមិនកាប់វា | ៥៩ |

| | | | |
|---|---|---|---|
| | ដីកសិកម្មពនេចរ | ភាគច្រើនមានចេក,អំពៅ,ដំឡូង, ពោត,សណ្តែក,ស្ពៃ. សាឡាត់..... | ១៦ |
| | ដីលំនៅដ្ឋាន ភូមិ | ចេក ដូង ដំឡូង ស្វាយ ល្ហុត ខ្នុរ ម្ទេស ស្លែ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ | ៩ |
| | ស្រូវវស្សា | - សំរាប់ស្រូវធ្ងន់ :នាងនូ,ក្រមួនស សូមាលី<br>- ស្រូវស្រាល : នាងខួន ក្រចកចាប ប្រវិកស<br>- ស្រូវកណ្តាល : ស្រូវដំណើប ចំបើងលឿង ប្រកិន | ២៣៧ |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

ផែនទីបង្ហាញផលិតភាពដី ឃុំកាចូន ស្រុកវើនសៃ ខេត្តរតនគីរី




**រូបភាព១០:**ផែនទីផលិតភាពដី

## ១.៣.៤ ធនធានធម្មជាតិ

### ១.៣.៤.១ ធនធានព្រៃឈើ

ធនធានព្រៃឈើជាផ្នែកមួយដ៏សំខាន់ នៃធនធានធម្មជាតិ ដែលមានមុខងារផ្នែកអេកូឡូស៊ី នឹង មុខងារផ្នែកសេដ្ឋកិច្ចសំរាប់ឃុំកាចូនព្រោះនៅក្នុងតំបន់នោះមានប្រភេទឈើមានតំលៃដូចជាឈើគគីរ ត្រាច ធ្នឹក សុក្រំ ឈើទាល ពពេល សាខាវ នាងនួន បេង ឆ្នុង ក្រញូង ដែលប្រភេទឈើទាំងនោះដុះនៅតាមព្រៃស្រោង និងនៅតាមភ្នំ ។ ចំណែកសត្វព្រៃ ដូចជា ឈ្លូស ប្រើស ជ្រូកព្រៃ ខ្ទីង សំបូរនៅតាមព្រៃស្រោង ។ បច្ចុប្បន្ននេះធនធានដែលមាន តំលៃទាំងនេះត្រូវបានបាត់បង់ បន្តិចម្តងៗដោយសារការបំផ្លាញពីក្រុមមនុស្សមួយចំនួន គួបផ្សំនឹងការប្រើប្រាស់មិន សមស្របរបស់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នប្រជាពលរដ្ឋនៅក្នុងឃុំ បាននិងកំពុងយកចិត្តទុកដាក់លើការ

ការពារធនធាន ព្រៃឈើ ក៏ដូចជាធនធានធម្មជាតិ សត្វព្រៃ ជីវៈ ចំរុះឡើងវិញ ដោយបង្កើតជាគំរោងសហគមន៍ព្រៃឈើ ។ល។

### ១.៣.៤.២ ធនធានជលផល

មួយផ្នែកនៃឃុំស្ថិតនៅជាប់ដងទន្លេសេសានដែលអាចអោយប្រជាពលរដ្ឋអាស្រ័យលើធនធានដែលបានមកអំពីទន្លេនេះ ដូចជា ត្រី ខ្យាច់ ឬផលនៃជីវៈចំរុះ ។ល ។ដែលជាប្រភពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមួយភាគធំដែលស្ថិតនៅជាប់ទន្លេ តែមកដល់បច្ចុប្បន្ននេះបើពិនិត្យលើស្ថានភាពជាក់ស្តែងសព្វថ្ងៃ នៅតាមដងទន្លេសេសានធនធានជលផលមានការថយចុះដូចជាត្រី និងជីវៈចំរុះដែលផលប៉ះពាល់នោះបានបណ្តាលមកពីការប្រើប្រាស់ឧបករណ៍នេសាទ ពុំសមស្រប និងការសាងសង់ទំនប់វារីអគ្គិសនីនៅប្រទេសវៀតណាមធ្វើអោយចរន្តទឹកទន្លេមានការឡើង-ចុះខុសរដូវ បណ្តាលអោយប៉ះពាល់ដល់ផលដំណាំ កសិកម្ម និងបន្លែដាំដុះនៅតាមច្រាំងមាត់ទន្លេរបស់ប្រជាពលរដ្ឋ។ សព្វថ្ងៃប្រពលរដ្ឋនៅក្នុងឃុំកាចូនពឹងពាក់ទៅលើតែប្រភពអូរតូចៗ នៅក្នុងឃុំប៉ុណ្ណោះដែលពួកគេអាចរកត្រី ក្តាម ខ្ចង នៅដងអូរនោះ ពីព្រោះមច្ឆាជាតិដែលសំបូរពីមុនមកនៅក្នុងទន្លេត្រូវបានថយចុះជាលំដាប់បណ្តាលអោយប្រជាពលរដ្ឋ ជួបការលំបាកជាខ្លាំងក្នុងការផ្គត់ផ្គង់ម្ហូបក្នុងគ្រួសារក៏ដូចជីវភាពប្រចាំថ្ងៃ។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

- តម្លៃស្រូវ ១ គីឡូក្រាម = ៨00រៀល
- អង្ករ ១គីឡូក្រាម = ២.៥00 រៀល
- សាចជ្រូក ១គីឡូក្រាម = ១២.000រៀល
- សាចត្រី ១គីឡូក្រាម = ១៣.000រៀល
- មាន់ ១ តំលៃ ២0.000 រៀល
- សាច់គោ ១គីឡូក្រាម = ១៨.000 រៀល
- គ្រឿងផ្ទះ ១ គូប = ៥00.000 រៀល
- ខ្សាច់ ១គូប = ១0.000 រៀល
- គ្រួស ១ គូប= ៣0.000រៀល

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- ការទិញចូលស្រូវ អង្ករ គឺទិញពីអ្នកភូមិជិតខាងនិងភូមិខ្លួនឯង និងមួយចំនួនតូចទិញពីឈ្មួញដែលបាននាំចូលស្រូវ-អង្ករទាំងនោះពីផ្សារបានលុងទៅ ។

- ការលក់ចេញនូវផល-អនុផលព្រៃឈើ ប្រជាជនបាននាំយកទៅលក់នៅទីរួមខេត្ត ជួនកាលមានឈ្មួញមកពីខាងក្រៅចូលមកទិញ ភាគច្រើនតម្រូវការរបស់ឈ្មួញ គឺឈើនិងអនុផលព្រៃឈើខ្លះៗ ។

- ចំពោះផលដែលបានពីការនេសាទវិញ គ្រាន់តែសំរាប់តែបង្គ្រប់នៅក្នុងជីវភាពគ្រួសារ ប្រចាំថ្ងៃតែប៉ុណ្ណោះ ព្រោះផលនេសាទដែលរកបានមិនគ្រប់តំរូវការសំរាប់លក់ចេញទៅក្រៅនោះទេ ។

### ១.៤.៣ ឱកាស និងឧបសគ្គ

ធនធានធម្មជាតិព្រៃឈើ ផ្តល់នូវផល-អនុផលព្រៃឈើសំរាប់ជាប្រភពចំណីអាហារ អុសដុត សំភារៈប្រើប្រាស់ជាប្រភពចំណូលសំរាប់ប្រជាជនមូលដ្ឋាន ដែលតែងតែពឹងពាក់អាស្រ័យមកដល់បច្ចុប្បន្នធនធានព្រៃឈើកំពុងទទួលរងការគំរាមកំហែង ហើយត្រូវបានបាត់បង់បន្តិចម្តងៗ ដោយសារការបំផ្លាញពីក្រុមមនុស្សមួយចំនួនរួមផ្សំនឹងការប្រើប្រាស់មិនសមស្របរបស់ប្រជាពលរដ្ឋ ។ កត្តាទាំងនេះបានធ្វើអោយឃុំកាចូនបាត់បង់ នូវចំនូលសេដ្ឋកិច្ចយ៉ាងធំ ដែលការបាត់បង់នេះជះឥទ្ធិពលមកដល់កូនចៅជំនាន់ក្រោយៗ ធ្វើអោយស្ថានភាពឃុំទាំងមូលជួបការលំបាកនិងប៉ះពាល់ជីវភាពរស់នៅយ៉ាងធ្ងន់ធ្ងរ ។

ចំណែកឯធនធានជលផល គឺជាប្រភេទធនធានផ្តល់នូវថាមពលយ៉ាងខ្លាំង ព្រោះវាជាតំរូវការចាំបាច់ នៃអាហាររបស់មនុស្សហើយក៏ជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំក៏ដូចជាសេដ្ឋកិច្ចជាតិ ។ បច្ចុប្បន្នការប្រើប្រាស់ធនធានមានភាពអនាធិបតេយ្យយ៉ាងខ្លាំងដូចជា ការបំពុល ឆក់ខ្សែភ្លើង ការប្រើមងមានក្រឡាតូច ។ល ។ធ្វើអោយពូជត្រីបាត់បង់ជាបន្តបន្ទាប់ព្រោះតែការធ្វើអាជីវកម្មពុំត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេសនិង ពុំស្តាប់តាមការណែនាំរបស់ស្ថាប័នជំនាញ ។ផលប៉ះពាល់ដ៏ធំមួយទៀតគឺមកបន្ទាលមក ពីការសាងសង់វារីអគ្គិសនីនៅប្រទេសវៀតណាម ដែលធ្វើអោយទឹកទន្លេមានសកម្មភាពខុសប្រក្រតី ជួនកាលស្រកអស់តែម្តង ជួនកាលទឹកអាចឡើង រីឯទឹកមានភាពល្អក់ ដែលធ្វើអោយមច្ឆាជាតិ និងជីវះចំរុះមួយភាគធំមិនអាចរស់នៅបាន និងមួយចំណែកធំប៉ះពាល់ដល់ ដំណាំកសិករ និងបន្លែធម្មជាតិដែលដុះនៅតាម ដងទន្លេ ។

# ជំពូក២
# ការវិភាគតម្រូវការសំរាប់អនាគត

## ២.១ តំបន់សើប

- **សហគមន៍ព្រៃឈើអណ្តូងព្រះនាង:** ឃុំកាចូនបានរៀបចំជាតំបន់ព្រៃសហគមន៍មួយកន្លែង គឺព្រៃសហគមន៍អណ្តូងព្រះនាងមានផ្ទៃដីសរុបប្រហែល ១៤០៨ហិចតា ជាតំបន់សំបូរដោយធនធានឈើប្រណិត។ និងជីវៈចំរុះច្រើនប្រភេទដែលមួយភាគនៃប្រភេទព្រៃជាព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងហើយដែលសហគមន៍នៅទីនោះធ្វើការការពារយ៉ាងតឹងតែងបំផុតក្នុងគោលបំណង រក្សាធនធានអោយនៅយូរអង្វែង ដើម្បីធានាការប្រើប្រាស់មានប្រសិទ្ធិភាព និងមាននិរន្តរភាព។ក្រៅពីនោះនៅមានព្រៃរបោះនិងព្រៃផ្សេង។ទៀតដែលអាចផ្តល់លទ្ធភាពអោយសត្វព្រៃជ្រកកោនរកចំណីអាហារនិងមនុស្សអាចទាញយកផល-អនុផលពីព្រៃទាំងនោះ។

សហគមន៍ព្រៃឈើអណ្តូងព្រះនាងត្រូវបានប្រជាពលរដ្ឋនៅក្នុងឃុំ បង្កើតឡើងដើម្បីការពារ និងថែរក្សាទុកជាសម្បត្តិធម្មជាតិដ៏មានតំលៃទៅអនាគត និងបាន កំណត់យកឈ្មោះខាងលើសំរាប់សំគាល់នូវឈ្មោះសហគមន៍នោះ។ ការបង្កើតសហគមន៍ព្រៃឈើនេះនៅមិនទាន់បានការទទួលស្គាល់តាមផ្លូវច្បាប់តាមលំដាប់លំដោយនៅឡើយទេ ( ឯកសារយោង: កិច្ចព្រមព្រៀង លក្ខន្តិកៈបង្កើត...បានឆ្លងដល់ដំណាក់ការ ណាហើយ...) ។

- **ដងទន្លេសេសាន:** តំបន់ស្ថិតនៅជាប់ដងទន្លេសេសានជាតំបន់សំបូរដោយធនធានមច្ឆា ដីមានជីជាតិផ្តល់លទ្ធភាពដល់ដំណាំចំការច្រើមុខសំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់។ បញ្ហាគួរចាប់អារម្មណ៍គឺចរន្តទឹក មានការប្រែប្រួលមិនទៀងទាត់ជួនមានទឹកច្រើនពេកបណ្តលអោយលេចផលដំណាំរបស់កសិករជួនកាលទៀតទឹកមានតិចតួចធ្វើអោយធនធានដែលមាននៅក្នុងទន្លេរងនូវផលប៉ះពាល់ជះឥទ្ធិពលដល់ការរស់នៅដល់ប្រជាជនក្នុងឃុំ កត្តាទាំងនេះ គឺអាស្រ័យដោយការធ្វើទំនប់វារីអគ្គីសនីនៅផ្នែកខាងលើនៃប្រទេសវៀតណាម។

- **ព្រៃអារក្ស:** ជាធម្មតាព្រៃអារក្សជាព្រៃដ៏មានសារៈសំខាន់សំរាប់ប្រជាជននៅក្នុងតំបន់ ដែលឃុំបានគិតគូរជាពិសេសក្នុងការថែរក្សាទុកជាកន្លែងគោរពសែនព្រេន និងបន់ស្រន់ទៅតាមប្រពៃណីរបស់ពួកគេហើយដែលព្រៃនេះពុំបាននិយាយទេនៅត្រង់ចំនុចនេះ តែបានរំលេចនៅចំនុចប្រើប្រាស់ដីអនាគត។

## ២.២ ការប្រឈម/ ឧបស័គ្គ

ឃុំកាចូនជួបបញ្ហាប្រឈមជាច្រើនក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការប្រើប្រាស់ដីដូចជា:

- ក្រុមប្រឹក្សាឃុំក៏ដូចជាសហគមន៍ ដែរកង្វះខាតការយល់ដឹងអំពីនីតិវិធីក្នុងការដោះស្រាយទំនាស់ផ្សេង។ជាពិសេសទំនាស់ដីធ្លី កើតចេញពីព្រំប្រទល់មិនច្បាស់លាស់ដែលភាគច្រើនបណ្តលមកពី ក៏រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងដីតាមភូមិនិមួយ។។

- ធនធានធម្មជាតិដែលមានត្រូវរងការគំរាមកំហែងដោយការប្រើប្រាស់ពុំសមស្រប របស់ប្រជាជនមូលដ្ឋាន និង ដោយការបំផ្លិចបំផ្លាញពីសំណាក់ជនខិលខូចមួយចំនួន ធ្វើអោយព្រៃឈើ សត្វព្រៃ ត្រីបាត់បង់ជាប់ណ្តើរ។ ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងឃុំ។

- បញ្ហាផ្លូវគមនាគមន៍ជាបញ្ហាដែលបានបង្ករអោយមានភាពអាក្រក់នៅក្នុងឃុំ ដោយសារផ្លូវមួយចំនួននៅក្នុងឃុំទទួលរងនូវការខូចខាតយ៉ាងខ្លាំង នៅរដូវវស្សាពិបាកក្នុងការធ្វើដំណើរ ក៏ដូចជាក្នុងការដឹកផលិតផលទៅកាន់ទីផ្សារ ។

- គ្រោះទឹកជំនន់កើតមានជារៀងរាល់ឆ្នាំបំផ្លាញផលនិងផលិតផលដំណាំយ៉ាងធ្ងន់ធ្ងរដែលសុទ្ធសឹងជះឥទ្ធិពលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ។

-លើសេវាអប់រំពុំមានអាគារគ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការ ឆ្លើយតបនឹងចំនួនសិស្សដែលមាននៅក្នុងឃុំនោះទេ ។ក្មេងគ្រប់អាយុចូលមតេយ្យ សិស្សអនុវិទ្យាល័យមានចំនួនច្រើនតែពុំមានអាគារនិងពុំមានគ្រូគ្រប់គ្រាន់ធ្វើអោយប្រជាពលរដ្ឋមានច្រើនលើសលប់ទៅដោយអនក្ខរជនដែលជាផលប៉ះពាល់យ៉ាងធ្ងន់ដល់សង្គមជាតិ ។

- ផ្នែកសេវាសុខាភិបាលនៅមានកង្វះខាត ព្រោះការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋអោយគេ យល់អំពីការថែទាំសុខភាព ការងារអនាម័យ នៅមានកំរិតក្នុងនោះស្ត្រីនិងកុមារជាអ្នកដែលងាយទទួលរងគ្រោះ ។

- ជាទូទៅទិន្នផលស្រូវនៅមានកំរិតទាបខ្លាំងកត្តាទាំងនេះគឺបណ្តាលមកពីការយល់ដឹងរបស់កសិករលើវិស័យបច្ចេកទេសកសិកម្មពុំទាន់ធានាបាន ហើយកត្តាមួយទៀតគឺដីខ្សោះជីជាតិប្រព័ន្ធស្រោចស្រពមិនអាចដោះស្រាយបានដោយប្រជាជនខ្វះខាតថវិកាក្នុងការទាញយកទឹកពីប្រភពសំរាប់ប្រើប្រាស់ ។

## ២.៣ តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំតាចូន

- ដើម្បីដោះស្រាយនូវបណ្តាបញ្ហាខាងលើនៅក្នុងជំហាននៃការអភិវឌ្ឍន៍ឃុំ យើងបានដាក់ចេញនូវគោលដៅជា យុទ្ធសាស្ត្រដោយបានលើកជាគម្រោងផែនការសំរាប់ពេលអនាគតដោយបានកំណត់នូវបណ្តាផែនការដែលជាអាទិភាព ដូចខាងក្រោម :

- ក្រុមប្រឹក្សាឃុំបានយកចិត្តទុកដាក់គិតគូរដល់ប្រជាពលរដ្ឋដោយបានគ្រោងរៀបចំកម្មវិធីផ្សព្វផ្សាយអំពីច្បាប់ភូមិបាល និងសិទ្ធិប្រើប្រាស់ដីអោយដល់មូលដ្ឋានអោយបានស៊ីជំរៅ តាមរយៈស្ថាប័នជំនាញ ឬអង្គការផ្សេងៗ ។

- ការសាងសង់ផ្លូវថ្នល់ ជាតំបូងត្រូវបានកំណត់យកការជួសជុលផ្លូវចាស់ដែលមានស្រាប់ និងការកសាងផ្លូវថ្មីដែលក្នុងនោះរួមមានៈការលើកផ្លូវដីស ការក្រាលគ្រួសក្រហម ក្រាលកៅស៊ូលើផ្លូវគ្រួសក្រហមព្រមជាមួយការរៀបចំជាសហគមន៍ថែទាំផ្លូវដើម្បីធានាអោយមានគុណភាពយូរអង្វែង ។

- ដើម្បីអោយមានប្រសិទ្ធិភាពក្នុងការបង្កើនទិន្នផលស្រូវទៅអនាគត ឃុំមានគោលការណ៍ក្នុងការរៀបចំស្តារ និងកសាងប្រឡាយរួមមានប្រឡាយមេ ប្រឡាយរង ដើម្បីអាចជំរុញដល់ការធ្វើស្រែបង្កើនរដូវផងដែរ ។

- លើវិស័យទឹកស្អាត និងការថែទាំសុខភាព អនាម័យជាបញ្ហាចំបងដែលឃុំបាន និងកំពង់ចាប់អារម្មណ៍ទៅលើគម្រោងផែនការសាងសង់អណ្តូងទឹករួមមាន អណ្តូងលូ អណ្តូងស្នប់ និង ធុងចម្រោះសំរាប់បំរើអោយការប្រើប្រាស់ទឹកស្អាត និងជំរុញការសាងសង់បង្គន់អនាម័យអោយបានច្រើនក្នុងមូលដ្ឋានឃុំទាំងមូល ។

- ដើម្បីបំពេញតំរូវការលើវិស័យសិក្សាអប់រំ ឃុំបានគិតគូរផងដែរលើការសាងសង់អាគារ សិក្សាបន្ថែមទៅលើសាលាចាស់ដែលមានរួចមកហើយ នឹងសង់បំពេញបន្ថែមបន្ទប់មួយចំនួន ចំពោះសាលាបឋមសិក្សា និងអនុវិទ្យាល័យ ។ ដោយឡែកចំពោះមតេយ្យសិក្សា ឃុំបានធ្វើការកំណត់ជ្រើសរើសទីតាំង ក្នុងការសាងសង់សាលាថ្មីនៅតាមបណ្តាភូមិ ដើម្បីធានាដល់ការសិក្សារបស់កុមារតូចៗ ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំ ។ ទន្ទឹមគ្នានេះដែរ ឃុំបានផ្តោតការយកចិត្តទុកដាក់ក្នុងការបើកថ្នាក់អក្ខរកម្ម នៅតាមភូមិ នៅពេលយប់ដោយប្រើប្រាស់សាលាមតេយ្យនេះ ។

- ដោះស្រាយនិងបង្កាទុកជាមុនតាមតែអាចធ្វើទៅបានចំពោះគ្រោះទឹកជំនន់ នោះ គឺត្រូវដឹងពីពេលវេលា និង ទីកន្លែងដែលនឹងត្រូវប៉ះពាល់ធ្វើយ៉ាងណាអោយការខូចខាតថយចុះត្រឹមកំរិតតូចបំផុត ។

- ចំពោះការថែរក្សាធនធានធម្មជាតិឃុំ ត្រូវរៀបចំសហគមន៍ ដើម្បីប្រើប្រាស់ និងគ្រប់គ្រងទៅលើការថែរក្សា និងអភិរក្សលើប្រភេទឈើប្រណិតៗ ឈើ និងអនុផលព្រៃឈើ ហើយនិងសត្វគ្រប់ប្រភេទដែលមាននៅក្នុងព្រៃ ។ ក្រៅពីនោះឃុំនៅបានគិតគូរផងដែរអំពីធនធានដែលមាននៅក្នុងទឹករួមបញ្ចូលនិងជីវចំរុះផងដែរ ។ ទាំងធនធានលើដីក្រោមដី និងក្នុងទឹកឃុំបាន យកចិត្តទុកដាក់ការពារយ៉ាងម៉ឺងម៉ាត់ដើម្បីជៀសវាងការលួចជ្រៀតចូលពីជនខិលខូច ។ ការអនុវត្តបាននូវយុទ្ធសាស្ត្រ នេះវាអាចផ្តល់នូវផលប្រយោជន៍ច្រើនយ៉ាងដល់ប្រជាជនក្នុងតំបន់ក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការដកយកផលពីធនធានធមជាតិទាំងនោះ ។

# ២.៤ តម្រូវការដីសំរាប់អនាគត

## ២.៤.១ ប្រជាសាស្ត្រ

### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃប្រជាពលរដ្ឋនៅក្នុងឃុំកាចូន បើពិនិត្យនៅក្នុងឆ្នាំ២០០៦ ឃើញថាមានការកើនឡើង១៥គ្រួសារចំពោះចំនួនមនុស្សឃើញថាមានចំនួនច្រើនជាងរហូតទៅដល់៥០២នាក់ស្មើ៤% ក្នុងឆ្នាំ២០០៧ គ្រួសារមានការកើនឡើង៤គ្រួសារតែចំនួនមនុស្សថយចុះ២១៩នាក់ និងនៅឆ្នាំ២០០៨ ចំនួនគ្រួសារមានការកើនឡើងច្រើនរហូតដល់ទៅ៣៧គ្រួសារតែប្រជាជនថយចុះវិញ១៤នាក់ ។ ពិនិត្យជារួមឃើញថា មិនមានការកើនឡើងជារៀងរាល់ឆ្នាំនោះទេ ផ្ទុយទៅវិញប្រជាពលរដ្ឋមានការផ្លាស់ទីលំនៅចេញក្រៅ ឬចេញទៅប្រកបមុខរបរនៅខាងក្រៅឃុំ ចំណែកប្រជាពលរដ្ឋផ្លាស់ទីលំនៅមកពីតំបន់ផ្សេងៗចូលមកក្នុងឃុំ គឺពុំសូវមានទេ ។

តារាង ការគណនាអត្រាកំណើនមធ្យម

| **ចំនួនគ្រួសារ/ប្រជាជន** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **អត្រាកំណើន** | **កំណើន/ឆ្នាំ** |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ៤០៥ | ៤២០ | ៤២៤ | ៤៦១ | - | - |
| អត្រាកំណើនគ្រួសារ | - | ៤% | ១% | ៩% | ៤% | ១៨គ្រួសារ |
| ចំនួនប្រជាជនសរុប | ១៨០០ | ២៣០២ | ២០៨៣ | ២០៦៩ | - | - |
| អត្រាកំណើនប្រជាជន | - | ២៨% | -១០% | -១% | ៦% | ១២៤នាក់ |

**ប្រភព:** ឯកសារពតិមាន ស្តីពីស្ថានភាពឃុំកាចូន ឆ្នាំ ២០០៩

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំកាចូន បើពិនិត្យទៅលើកំណើន ក្នុងរយៈពេល៥ ឆ្នាំម្តង សំរាប់រយៈពេល១៥ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យម៦%ស្មើនឹង១២៤នាក់ក្នុង១ឆ្នាំ បើគិតជាគ្រួសារឃើញថាមានការកើនឡើង ១៨គ្រួសារក្នុងមួយឆ្នាំប៉ុណ្ណោះ។ ដូច្នេះប្រសិនបើអត្រាកំណើនប្រជាសាស្ត្រនេះរក្សាដូចនេះរហូតដល់ឆ្នាំ២០២២ យើងអាចធ្វើការប៉ាន់ប្រមាណ អំពីកំណើនប្រជាសាស្ត្រដូចមានបង្ហាញក្នុងតារាងខាងក្រោម។

**<u>តារាងការធ្វើចំណោលប្រជាសាស្ត្រ</u>**

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| អាយុក្រោម០៥ឆ្នាំ | ៣៧៣ | ១៩១ | ៤៦៣ | ២៣៧ | ៥៥៤ | ២៨៣ | |
| អាយុ ០៥ឆ្នាំ | ១២៩ | ៧៤ | ១៦០ | ៩២ | ១៩១ | ១១០ | |
| អាយុពី ៦-១១ឆ្នាំ | ៣៧១ | ១៨៣ | ៤៦០ | ២២៨ | ៥៥០ | ២៧២ | |
| អាយុពី ១២-១៤ឆ្នាំ | ២៣១ | ១០៩ | ២៨៦ | ១៣៥ | ៣៤២ | ១៦២ | |
| អាយុពី ១៥-១៧ឆ្នាំ | ២៦០ | ១២១ | ៣២៣ | ១៥១ | ៣៨៦ | ១៨០ | |
| អាយុពី ១៨-២៤ឆ្នាំ | ២៤៣ | ១៣១ | ៣០២ | ១៦៣ | ៣៦០ | ១៩៥ | |
| អាយុពី ២៥-៦០ឆ្នាំ | ៨៣២ | ៣៦២ | ១០៣៣ | ៤៥០ | ១២៣៤ | ៥៣៧ | |
| អាយុពី៦១ឆ្នាំឡើងទៅ | ១២៦ | ៦៨ | ១៥៧ | ៨៥ | ១៨៨ | ១០១ | |
| **ចំនួនប្រជាជនសរុប** | **២៥៦៥** | **១២៤១** | **៣១៨៥** | **១៥៤១** | **៣៨០៥** | **១៨៤១** | |
| **ចំនួនគ្រួសារសរុប** | **៥៧២** | | **៧១០** | | **៨៤៨** | | |

## ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋាននៅជនបទគឺសំដៅទៅដល់ដីដែលប្រើប្រាស់សំរាប់សង់ផ្ទះនិងសំរាប់ដាំដំណាំសួនគ្រួសារនៅជុំវិញផ្ទះ(លំអិតសូមមើលឧបសម្ព័ន្ធ១)សំរាប់ឆ្នាំគោល២០០៨ មានទំហំ ៩ហិកតា សំរាប់ប្រជាជនប្រមាណជា ៣៩៥[១] គ្រួសារដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺមានប្រហែល ០,០២៣ ហិកតា គឺតិចជាងដីសំរាប់សង់លំនៅដ្ឋានដែលមាន ១២០០-៣៦០០ម២ (មាត្រាទី១៥ ជំពូក៥នៃអនុក្រិត្យ ស្តីពីសម្បទានដីសង្គមកិច្ច)។ អាស្រ័យ ដោយនៅក្នុងឃុំកាចូនដីពុំមានវិសាលភាពគ្រប់គ្រាន់ ដូច្នេះក្នុងការប៉ាន់ប្រមាណដីសំរាប់សង់លំនៅដ្ឋានត្រូវកំណត់យក១២០០ម$^{២}$ ។ដើម្បីធានាអោយប្រជាជនដែលខ្វះដី មានដីមិនគ្រាន់គ្រាន់និងប្រជាជនដែលកើនឡើងនៅឆ្នាំ ២០២២ មានដីលំនៅដ្ឋានសមរម្យយើងត្រូវពិចារណាដូចខាងក្រោម៖

**តម្រូវការសំរាប់ឆ្នាំ ២០២២ គឺ :**

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន ៦៦ គ្រួ. x 0,១២ = ៨,0 ហត.
- ចំនួនគ្រួសារដែលនៅខ្វះដីលំនៅដ្ឋាន ៣៩៥គ្រួ x (0,១២-0,0២៣) = ៣៨,0 ហត.
- កំណើនគ្រួសារ ២០២២ ៣៨៧គ្រួ. x 0,១២ = ៤៦,0 ហត.

**សរុប ៩២ ហត.**

តាមការគណនាខាងលើឃើញថានៅឆ្នាំ២០០៩យើងត្រូវការដី៨ហិចតាសំរាប់គ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន និង៣៩ហិចតា ទៀតសំរាប់គ្រួសារ ដែលនៅខ្វះដីលំនៅដ្ឋាន។ ចំណែកនៅឆ្នាំ២០២២យើងត្រូវការដីតែ៤៦ហិចតាប៉ុណ្ណោះសំរាប់កំណើន ៣៨៧គ្រួសារ។

ផ្អែកតាមតួលេខដែលបានគណនាខាងលើដោយយកទំហំដីលំនៅដ្ឋានធំបំផុតនៃទំរង់ដីសម្បទានសង្គមកិច្ចមកគិតទៅតាមចំនួនគ្រួសារដែលមាន និងដែលត្រូវកើនឡើងគឺត្រូវការដីរហូតដល់៩២ហិចតាដូច្នេះយើងត្រូវពិចារណា លើដីលំនៅដ្ឋានដែលបច្ចុប្បន្នមានតែ៩ហិចតា ហើយនិងដីតំរូវការក្នុងអំឡុងពេល១៥ឆ្នាំខាងមុខទៀត។

## ២.៤.៣ តម្រូវការដីកសិកម្ម

តំរូវការដីកសិកម្មគឺនិយាយចំពោះតែដីស្រែវស្សានិងដីចំការដំណាំតែប៉ុណ្ណោះ(លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល២០០៨ ដីកសិកម្មមានទំហំ១២៩៣ហិចតាជាមួយនឹងចំនួនគ្រួសារ សរុប៤៦១ បើគិតជាមធ្យមក្នុងមួយគ្រួសារមានដីប្រមាណជា ២,៨០ហិចតា លើសពីដីសំរាប់ធ្វើកសិកម្មដែលមាន ២ហិចតា (មាត្រាទី១៧ ជំពូក៥នៃអនុក្រិត្យ ស្តីពីសម្បទានដីសង្គមកិច្ច)។ក្នុងចំនួននេះយើងសង្កេតឃើញថាចំនួនដីកសិកម្មគឺពុំទាន់ខ្វះខាតនៅឡើយទេ ហើយបើនិយាយពីការប្រើប្រាស់ជាក់ស្តែងរបស់ឃុំគឺត្រឹមតែ២.00ហិកតា ប៉ុណ្ណោះក្នុងមួយគ្រួសារ។ ការប្រើប្រាស់ដីកសិកម្មនៅឆ្នាំ២០០៩ ពុំទាន់ចោទជាបញ្ហាទេបញ្ហាដែលយើងត្រូវគិតគឺ កំណើនគ្រួសារនៅឆ្នាំ ២០២២ ដែលគួរមានដូច ខាងក្រោម:

**សំរាប់ឆ្នាំ ២០២២ គួរមាន:**

- ចំពោះគ្រួសារបច្ចុប្បន្នមិនទាន់មានដីកសិកម្ម ៨៣គ្រx ១,៥0 = ១២៤.៥0 ហិចតា
- ចំពោះគ្រួសារមានដីតិចជាង១ហិកតា ៩២គ្រួ x (១.៥0-0.៥0) = ៩២ ហិចតា
- កំណើនគ្រួសារ២០២២ ៣៨៧គ្រួ x ១,៥0 = ៥៨0,៥0 ហិចតា

សរុប **៧៩៧,00ហត.**

តាមការគណនាខាងលើបង្ហាញអោយឃើញថាតើទំហំដីដែលមាននាពេលបច្ចុប្បន្នវាមានតុល្យភាពជាមួយនឹងចំនួនប្រជាជនឬទេដែលជាលទ្ធផលឃើញថាទំហំដីដែលកំពុងប្រើប្រាស់ បើគិតជាមធ្យមតាមគ្រួសារឃើញថាប្រើប្រាស់ដីតែ ៩២២ហត ប៉ុណ្ណោះក្នុងចំនួនដីដែលមាន ១២៩៣ហត ។ តែតំរូវការនៅឆ្នាំ២០២២ត្រូវមានទំហំ ៧៧៤ហត ហើយនិងចំនួនដីដែលនៅសល់គឺយើងត្រូវការពង្រីកដីបន្ថែម ៤០៣ហតសំរាប់ដីកសិកម្ម។ ចំនួននេះលើសពីទំហំដីដែលបានគិតទុកមានតែ២៦១ហិចតាសំរាប់រយៈពេល១៥ឆ្នាំ ដូច្នេះយើងគួរមានដី១,៥ហិចតា សំរាប់

មួយគ្រួសារជាការគ្រប់គ្រាន់ព្រោះទំហំនេះឆ្លើយតបទៅនឹង កំណើនគ្រួសារឆ្នាំ២០២២ដែលត្រូវការដី២០៩.៥ហិចតាប៉ុណ្ណោះ។

### ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយឃុំកាចូនមានតំបន់ព្រៃសហគមន៏មួយកន្លែង គឺព្រៃសហគមន៏អណ្តូងព្រះនាង មានផ្ទៃដីសរុបប្រហែល១.៤០៨ ហិចតាជាតំបន់សំបូរដោយធនធានឈើប្រណិត១ និងជីវៈចំរុះច្រើនប្រភេទ ព្រោះថាតំបន់នេះយើងបាន កំណត់នៅក្នុងតំបន់រសើប ហើយតំបន់រសើបនេះយើងតំរូវអោយមានកិច្ចការពារជាពិសេសពោលគឺនិរន្តរភាពនៃធន ធានធម្មជាតិ ក្រៅពីនេះសហគមន៏បានរៀបចំជាតំបន់អភិរក្សសត្វព្រៃដោយកំណត់យក២កន្លែងមានផ្ទៃដីសរុប ២២២ហិកតា សំរាប់កិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ និងមួយផ្នែកនៃទន្លេសេសានដែលយើងត្រូវអភិរក្ស ធនធានមច្ឆាជាតិ និងធនធានផ្សេង១ទៀតដែលមាននៅក្នុងទន្លេ។

### ២.៤.៥ តម្រូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម

ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺគេរាប់បញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជនពុំបាច់ញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច កន្លែងគោរពបូជា ។ល។) លើកលែងតែហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការ គិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធសង្គមត្រូវបានកំណត់ជារួមជាមួយនឹងដីត្រៀមបំរុង សំរាប់ពង្រីកទីប្រជុំជន។

តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គមនៅទីនេះគឺឃុំបានត្រៀមដីបំរុងទុកចំនួន៩ហិកតា ចំណែកផ្លូវនិងប្រឡាយមិនមានការគិតជាផ្ទៃដីទេ តែត្រូវគិតជាប្រវែងហើយនឹងបង្ហាញក្នុងផែនទីដោយឡែក។

**តារាងផែនការអភិវឌ្ឍន៏ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ**

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ០ | ០១ | ០១ |
| សាលាបឋមសិក្សា | ០៥ | ០៥ | ០ អាគារ |
| សាលាអនុវិទ្យាល័យ | ០ | ១សាលា | ០១ |
| សាលាវិទ្យាល័យ | ០ | ០ | ០ |
| មណ្ឌលសុខភាព | ០១ | ០១ | ០ |
| ប៉ុស្តិសុខភាព | ០ | ០ | ០ |
| ស្រះទឹកស្អាត | ០ | ០ | ០ |
| អណ្តូងទឹកស្អាត | ២៩ | ២៩ | ០ |
| កន្លែងចាក់សំរាម | ០ | ០១ | ០១ |
| ប៉ុស្តិនគរបាល | ០១ | ០១ | ០ |

ប្រភព: ការប្រជុំពិភាក្សានៅថ្នាក់ឃុំ

### ២.៤.៥.១ តម្រូវការសាលារៀន

ផ្ទៃដីសំរាប់កសាងសាលារៀន មិនចាំបាច់កំណត់ផ្ទៃដីបន្ថែមផ្សេងទៀតនោះទេជាធម្មតាផ្ទៃដីនេះគឺត្រូវបានរាប់បញ្ចូលទៅក្នុងដីភូមិពោលគឺដីលំនៅដ្ឋានហើយដែលបានគណនារួចខាងលើ។ បើតំរូវអោយមានការសាងសង់បន្ទប់រៀនថ្មីនោះគឺអាចពង្រីក តំឡើងសាលាចាស់ដែលមានស្រាប់ហើយសាងសង់បន្ទប់បន្ថែម។ ក្នុងករណីមានការសាងសង់ជាសាលាថ្មីជាចាំបាច់នោះទើបយើងត្រូវការគណនាដី។ ទោះជាយ៉ាងណាសាលារៀននៅឃុំកាចូនពុំអាចបំពេញតំរូវការសិស្សដែលបានកើនឡើងនោះទេ។ ដោយសង្កេតទៅលើចំនួនសិស្សដែលកើនឡើងនេះសំរាប់រយៈពេល១៥ឆ្នាំខាងមុខតំរូវអោយមានសាលាក្នុងកំរិតបឋមសិក្សា១ខ្នងរួមមាន៣បន្ទប់ អនុវិទ្យាល័យ ១ខ្នងមាន៣បន្ទប់ វិទ្យាល័យ១ខ្នងមាន៣បន្ទប់ និងថ្នាក់មត្តេយ្យមាន២បន្ទប់ តែពុំមានសាលានោះទេ។

**<u>តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២</u>**

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ១២៩ | ០ | ១ | ១៦០ | ០ | ០ | ១៩១ | ០ | ២ |
| ថ្នាក់បឋមសិក្សា | ៣៧១ | -១ | -៧ | ៤៦១ | -១ | -៣ | ៥៥០ | ១ | ៣ |
| ថ្នាក់អនុវិទ្យាល័យ | ២៣១ | ០ | ២ | ២៨៦ | ០ | ១ | ៣៤២ | ១ | ៣ |
| ថ្នាក់វិទ្យាល័យ | ២៦០ | ១ | ៣ | ៣២៣ | ០ | ១ | ៣៨៦ | ១ | ៣ |

### ២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

#### ក. សេវាកម្មសុខភាព

នាពេលបច្ចុប្បន្នឃុំកាចូន មានតែមណ្ឌលសុខភាពមួយប៉ុណ្ណោះ ចំណែកប៉ុស្តិ៍សុខភាពនៅពុំទាន់មាននៅឡើយទេនៅទូទាំងឃុំ។ ដើម្បីជួយសំរួលដល់ការទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋ ឃុំគួរមានប៉ុស្តិ៍សុខភាពមួយបន្ថែម ទៀត ព្រោះថាឃុំនេះមានភូមិមួយចំនួននៅត្រើយម្ខាងទន្លេពិបាកក្នុងការធ្វើដំណើរដឹកជញ្ជូនអ្នកជំងឺឆ្លងកាត់ទន្លេ និងអាចកាត់បន្ថយសោហុយធ្វើដំណើរទៀតផង។ ដូច្នេះក្រុមប្រឹក្សាឃុំគួរផ្តោតការយកចិត្តទុកដាក់លើសេវាសុខភាពដើម្បីធានានូវសុខមាលភាពជូនប្រជាពលរដ្ឋរបស់ខ្លួនអោយបានល្អប្រសើរ។

#### ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំកាចូនបច្ចុប្បន្ន នៅតែជាបញ្ហាចំបងនៅឡើយ ព្រោះថាអណ្តូងទឹកដែលមាននៅក្នុងឃុំដែលបានសាងសង់ពីមុននោះតូវបានខូចខាតមួយចំនួន តាមតួលេខអោយដឹងថាក្នុងចំណោមអណ្តូង ២៩ ប្រើការបានតែ២៣ប៉ុណ្ណោះ ដូច្នេះជាដំណោះស្រាយគឺត្រូវស្តារនិងជួសជុលនូវប្រភពទឹកស្អាតចំនួន៦ ហើយជាផែនការនៅពេលអនាគតឃុំគួរបន្ថែមនូវគម្រោងផែនការក្នុងការជីកអណ្តូងទឹកស្អាតយ៉ាងតិច២អណ្តូងទៀតសំរាប់ ២ភូមិដែលកន្លងមកពុំទាន់មានអណ្តូងទឹកស្អាតគឺភូមិកាចូនលើនិងភូមិកាឡឹមព្រមទាំងផ្តល់ជូននូវធុងចម្រោះ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

ផ្អែកតាមតារាងស្ថិតិជនជាតិ ដែលបានបង្ហាញនៅក្នុងជំពូក១ ខាងលើយើងឃើញថាប្រជាជននៅក្នុងឃុំកាចូន ស្ទើរតែ ១០០%ជាជនជាតិដើមភាគតិចចំណែកជនជាតិផ្សេងៗទៀតដែលកាន់ព្រះពុទ្ធសាសនាគឺមានតិចតួចបំផុត។ លើបញ្ហានេះយើងគួរគិតគូរជាពិសេសទៅលើវប្បធម៌ប្រពៃណីសាសនាតាមបែបជនជាតិភាគតិចពោលគឺរក្សាដីទុកសំរាប់ការគោរពទៅលើជំនឿរបស់ពួកគេរួមមានកន្លែងកប់ខ្មោច១កន្លែងមានផ្ទៃដី ៧ហិកតា និង ព្រៃអារក្ស១កន្លែងមានផ្ទៃដី ១២ហិកតា។ ក្រៅពីនេះពួកគេប្រារព្ធធ្វើពិធីផ្សេងៗនៅក្នុងភូមិរបស់ពួកគេដូចជា: សែនភូមិកាប់ក្របីផឹកស្រាជាដើម ។ល។ ចំណែកជនជាតិខ្មែរឡាវដែលមាន ចំនួនតិចតួចទើបតែទៅរស់នៅទីនោះហើយដែលនិយមកាន់ព្រះពុទ្ធសាសនានោះគឺអាចទៅកាន់វត្តអារាម ដែលនៅឃុំជិតជាប់នឹងឃុំកាចូនបាន។ ដូច្នេះតំរូវការដីសំរាប់ អភិវឌ្ឍន៍ ផ្នែកព្រះពុទ្ធសាសនានៅពុំទាន់ចាំបាច់នៅឡើយ។

<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>

| **វប្បធម៌ និងសាសនា** | **ចំនួនក្នុងឆ្នាំនេះ** | **ចំនួន១៥ឆ្នាំក្រោយ** | **បំរែបំរួល** |
|---|---|---|---|
| សាលាឆទាន | 0 | 0 | 0 |
| ទីកន្លែងសាការៈបូជា | 0 | 0 | 0 |
| វត្តអារាម | 0 | 0 | 0 |
| កន្លែងកប់ខ្មោច | ១ | ៥ | ៤ |
| ព្រៃអារក្ស | ១ | ១ | 0 |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមស្ថានភាពជាក់ស្តែង នៃបរិមាណផ្លូវដែលមានក្នុងឃុំកាចូនឃើញថាផ្លូវក្រាលគ្រួសក្រហម ដែលបានសាងសង់ពីមុនមកមានចំនួន១៥គម បច្ចុប្បន្នត្រូវបានខូចហើយនៅក្នុងឆ្នាំ២០០៩ នេះឃុំបានធ្វើការជួសជុលឡើងវិញបានមួយចំនួន និងមួយចំនួនទៀត នឹងធ្វើការជួសជុលបន្តហើយនៅរយៈពេល១៥ឆ្នាំខាងមុខឃុំនឹងលើកគម្រោងសាងសង់ផ្លូវ គ្រួសក្រហមបន្ថែមប្រវែង ១២គម ទៀតជាមួយគ្នានេះដែរឃុំក៏បានលើកគម្រោងផ្លូវក្រាលកៅស៊ូ ដែលមានប្រវែង ១២ គមដែលកន្លងមកពុំទាន់មាន ។

ដោយឡែកចំពោះផ្លូវថ្មើរជើង ឬ ផ្លូវរទេះដែលមានស្រាប់ប្រវែង ៩,៦៤គម នោះគឺឃុំនឹងធ្វើការសិក្សាលើកគំរោងចាក់គ្រួសក្រហមរយៈពេល១៥ឆ្នាំខាងមុខ។ ក្រៅពីនេះឃុំនៅមានគំរោងសង់ស្ពានឈើ អោយបានចំនួន ១៤ស្ពានបន្ថែមពីលើស្ពានឈើដែលមានស្រាប់ចំនួន ៧ស្ពាន និងសង់លូឆ្លងផ្លូវអោយបានចំនួន ៩បន្ថែមទៀតពីលើលូ ដែលមានស្រាប់ចំនួន៥លូ នៅ១៥ឆ្នាំទៀតព្រោះលូនិងស្ពានឈើដែលមានពុំទាន់អាចបំពេញតំរូវការការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅឡើយ។

អំពីប្រពន្ធ័ទឹកនៅឃុំកាចូនក្នុងឆ្នាំ២០០៨រួមមានប្រឡាយមេ ១៥គ.ម និងប្រឡាយរង ៩០០ម និងទ្វារទឹក ១២ បញ្ហានេះឃុំពុំតំរូវអោយពង្រីកបន្ថែមទៀតទេសំរាប់១៥ឆ្នាំខាងមុខដោយហេតុថាស្ថានភាពភូមិសាស្រ្តឃុំកាចូនភាគច្រើនជាដីខ្ពង់រាបដែលមិនអំណោយផល សំរាប់ប្រព័ន្ធស្រោចស្រព្វទេចង់ពង្រីកប្រព័ន្ធស្រោចស្រព្វគឺត្រូវចំណាយថវិកាខ្ពស់ដើម្បីទិញម៉ាស៊ីនបូមទឹកពីទន្លេដើម្បីចែកចាយតាមប្រព័ន្ធ ហើយដែលឃុំពុំមានលទ្ធភាព។

**<u>តារាងការអភិវឌ្ឍន៏ហេដ្ឋាផ្នែករចនាសម្ព័ន្ធរូបវ័ន្ត</u>**

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | 0 | ១២ | ១២ |
| ផ្លូវក្រាលគ្រួសក្រហម | ១២ | ២៤ | ១២ |
| ប្រវែងផ្លូវក្រាលដីស | 0 | 0 | 0 |
| ផ្លូវរទេះ/ថ្មើជើង | ៩,៦៤ | ៩,៦៤ | 0 |
| ប្រឡាយមេ | ១,៥ | ១.៥ | 0 |
| ប្រឡាយរង | 0,៩ | 0.៩ | 0 |
| ចំនួន ស្ពានថ្ម | 0កន្លែង | 0 កន្លែង | 0 កន្លែង |
| ចំនួនស្ពានឈើ | ៩កន្លែង | ១៤ កន្លែង | ៥កន្លែង |
| ចំនួន ទ្វារទឹក | ១២ ទ្វារ | ១២ទ្វារ | 0ទ្វារ |
| ចំនួនលូឆ្លងផ្លូវ | ៥ | ៩ | ៤ |

# ជំពូក ៣

# ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ ២០០៩ ដល់ ២០២២

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

ឃុំកាចូន មានធនធានដែលមានស្រាប់ដូចជា ស្ថានភាពដី ធនធានព្រៃឈើ ធនធានជលផល ដែលអាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ និងអភិរក្ស អភិវឌ្ឍន៍ ទៅលើធនធានទាំងនោះអោយមាននិរន្តរភាពជាពិសេសគឺការការពារបរិស្ថានធម្មជាតិមួយដ៏ល្អប្រសើរសំរាប់មជ្ឈដ្ឋានរស់នៅនៅក្នុងតំបន់នោះ។ នៅក្នុងទឹកមានជីវៈចំរុះនិងពពួកមច្ឆាច្រើនប្រភេទបង្កើតបានជាប្រពន្ធ័អេកូឡូស៊ី ដែលយើងត្រូវថែរក្សាអោយបានគង់វង្ស រីឯនៅក្នុងព្រៃវិញសំបូរដោយសត្វព្រៃដូចជាៈ អណ្តើក កន្ធាយ ពស់ ស្វា អន្សង ត្រកួត ប្រើស ឈ្លូស ខ្ទីង ខ្លាជ្រូកព្រៃ។ល។ និងសត្វ ស្លាបជាច្រើនប្រភេទទៀត ទាំងនេះ គឺជាសក្តានុពល មួយដែល ផ្តល់នូវសារៈប្រយោជន៏ដល់ប្រជាពលរដ្ឋនៅក្នុង មូលដ្ឋាន សំរាប់ការទាញយកអនុផលពីព្រៃឈើ ដូចជា វល្លិ៍ ផ្តៅ ជ័រទឹក ឬស្សី រុក្ខជាតិឱសថសំរាប់ព្យាបាលជំងឺផ្សេងៗ និងជារបាំងការពារខ្យល់ ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

ផ្អែកលើអត្រាកំណើនប្រជាពលរដ្ឋនៅឃុំកាចូន ចាំបាច់ត្រូវតែមានការកើនឡើងនូវតំរូវការប្រើប្រាស់ដីដែលតំរូវអោយឃុំមានការគិតគូរទៅលើនធនធាន ដែលមានស្រាប់ដោយធ្វើយ៉ាងណាអោយការប្រើប្រាស់មានសិទ្ធិភាព។ក្នុងន័យនេះឃុំបានរៀបចំចេញជាគំរោងផែនការទៅលើដីដោយធ្វើការផ្លាស់ប្តូរព្រៃរបោះនិងដីស្រូវវស្សា ១ហិកតាមួយកន្លែងនិងព្រៃរបោះ១ហិកតាមួយកន្លែងមកជាដីសាលារៀន។ចំណែកដីភូមិឃុំពុំមានផែនការផ្លាស់ប្តូរឬពង្រីកបន្ថែមទេព្រោះស្ថានភាពជាក់ស្តែងនៃភូមិសំរាប់រយៈពេល១៥ឆ្នាំខាងមុខនៅមិនទាន់ខ្វះខាតនោះទេ។

- ដីកប់ខ្មោចវាមានសារៈសំខាន់ណាស់សំរាប់ប្រជាជន ដែលជាជនជាតិភាគតិចព្រោះជាជំនឿ និងប្រពៃណីទំនៀមទំលាប់របស់ពួកគេឃុំមានគំរោងផែនការយកដីពីព្រៃរបោះចំនួន២កន្លែងមានផ្ទៃដី៥ហិកតានិងពីដីកសិកម្មពនេចរចំនួន២កន្លែងទៀតមានផ្ទៃដី២ហិកតា សរុបមានចំនួន៧ហិកតាសំរាប់ធ្វើជាកន្លែងកប់ខ្មោចសំរាប់រយៈពេល ១៥ឆ្នាំខាងមុខ។

- តំបន់អភិរក្សសត្វព្រៃជាតំបន់ដែលត្រូវថែរក្សាដើម្បីភាពគង់វង្សនៃពពួកសត្វព្រៃគ្រប់ប្រភេទអោយមាននិរន្តរភាព ក្នុងរយៈពេល១៥ឆ្នាំទៀតឃុំបានជ្រើសរើសព្រៃស្រោងសើមចំនួន២កន្លែង មានផ្ទៃសរុប២២២ហិកតាសំរាប់អភិរក្សនិងគ្រប់គ្រង។

- ព្រៃអារក្សគឺជាតំបន់សំរាប់ការគោរពបូជាតាមជំនឿរបស់ប្រជាជនដែលរស់នៅទីនោះ ព្រោះពួកគេពុំមានការគោរពតាមបែបសាសនាដូចប្រជាជនខ្មែរយើងទេ ដូច្នេះឃុំបានជ្រើសយកព្រៃស្រោងសើមមួយកន្លែងមានផ្ទៃដីប្រមាណជា១២ហិកតាសំរាប់ជាព្រៃអារក្ស នៅរយៈពេល១៥ឆ្នាំទៀត។

- ដីស្រែវស្សាជាដីដែលត្រូវការជាចាំបាច់សំរាប់ដាំដំណាំស្រូវព្រោះស្រូវផ្តល់អោយនូវប្រភពស្បៀងអាហារដ៏មានសារៈសំខាន់ក្នុងការចិញ្ចឹមជីវិតមនុស្សផងទាំងពួង ។ក្នុងន័យនេះឃុំបានជ្រើសយកដីកសិកម្មពនេចរ ២កន្លែងមានផ្ទៃដី១៨១ហិកតានិងដីព្រៃរបោះ១កន្លែងមានផ្ទៃដី២២ហិកតាសំរាប់ធ្វើជាដីស្រែវស្សាសំរាប់រយៈ ពេល១៥ឆ្នាំខាងមុខ ។

- ដីកសិកម្មពនេចរដីចំការដែលប្រជាជនជនជាតិទំលាប់ ធ្វើជាប្រពៃណីជារៀងរហូតមកព្រោះដីត្រូវទុកចោលយូរឆ្នាំអោយមានជីជាតិទើបកាប់ឡើងវិញដូច្នេះក្នុងរយៈពេល១៥ឆ្នាំទៀតឃុំធ្វើការផ្លាស់ប្តូរព្រៃរបោះ១កន្លែងដែល មានផ្ទៃដីប្រមាណជា ៦២ហិកតាសំរាប់ធ្វើជាដីកសិកម្មពនេចរ ។

<u>តារាងតម្រូវការនៃការប្រើប្រាស់ដីពេលអនាគត</u>

| ការប្រើប្រាស់ដីធ្លី | លេខកូដក្បាលដី | ក្រឡាផ្ទៃឆ្នាំនេះ( ហិចតា) | ក្រឡាផ្ទៃសំរាប់១៥ឆ្នាំខាងមុខ( ហិចតា) | បំរែបំរួល ( ហិចតា) |
|---|---|---|---|---|
| ដីសំរាប់កប់ខ្មោច | F1320 | 0 | ៧ | ៧ |
| តំបន់អភិរក្សសត្វព្រៃ | F6600 | 0 | ១៨៧២ | ១៨៧២ |
| ព្រៃអារក្ស | F3740 | ១៨៤ | ១៨៤ | 0 |
| ដីស្រែវស្សា | F2110 | ៣៣៥ | ៥៣៤ | ១៩៩ |
| ដីកសិកម្មពនេចរ | F2400 | ៩៥៧ | ១០១៩ | ៦២ |
| **សរុប** | | **១៤៧៦** | **៣៦១៦** | **២១៤០** |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់ដី

### ៣.២.១ ការវិភាគអន្តរអំពើ

ការប្រើប្រាស់ដីសំរាប់ពេលអនាគត១៥ឆ្នាំទៀត ជៀសមិនផុតពីការប៉ះពាល់ទៅលើផ្នែកណាមួយនៃវិស័យសេដ្ឋកិច្ចសង្គមកិច្ច និងបរិស្ថាននោះទេ ព្រោះថាការប្រែប្រួលពីស្ថានភាពដីមួយទៅស្ថានភាពដីមួយទៀតតែងតែជះឥទ្ធិពលដល់ការរស់នៅក៏ដូចជាការគ្រប់គ្រងជាក់ស្តែងដូចជាៈ

- ការប្រែប្រួលពីព្រៃរបោះនិងស្រូវវស្សាមកជាដីសាលារៀន ធ្វើអោយផ្ទៃដីព្រៃរបោះថយចុះបាត់បង់ព្រៃប្រភេទនេះដែលជាផ្នែកមួយនៃធនធានព្រៃឈើ ។ ចំពោះដីស្រូវវស្សាវិញវាបាត់បង់ដីសំរាប់ធ្វើស្រូវដែលតែងតែធ្វើជារៀងរហូតមក តែឃុំគិតដូចនេះព្រោះថាផលដែលបានមកពីស្រូវវស្សា មានផលចំណេញតិចតួចជាងហើយម្យ៉ាងទៀតដីស្រូវវស្សានោះពុំមានជីជាតិសំរាប់ដំណាំស្រែតទៅទៀត ។

- ការប្រែពីព្រៃរបោះនិងដីកសិកម្មពនេចរមកជាកន្លែងកប់ខ្មោចក៏មិនខុសពីខាងលើដែរ ។ ដីកសិកម្មពនេចរវាមានសារៈប្រយោជន៏សំរាប់ដំណាំចំការ ក៏ពិតមែនតែជាទំលាប់របស់បងប្អូនជនជាតិគឺគាត់ដាំតែដំណាំស្រាល១

ប៉ុណ្ណោះពុំដាំដំណាំរយៈពេលវែងនោះទេស្របជាមួយ នឹងដីពុំសូវមានជីជាតិផងនោះឃុំបានយកដីនោះជាកន្លែងកប់ខ្មោចព្រោះទីកប់ខ្មោចវាមានប្រយោជន៏ច្រើនជាងចំពោះការគោរពរបស់ប្រជាពលរដ្ឋ។

- ការអភិរក្សសត្វព្រៃជាផ្នែកមួយនៃការគ្រប់គ្រងធនធានធម្មជាតិអោយមាននិរន្តរភាព ក្នុងនោះឃុំបានរើស យកព្រៃស្រោងសើមចំនួន២កន្លែងសំរាប់ជាតំបន់អភិរក្សសត្វព្រៃ ប្រការនេះពុំមានផលប៉ះពាល់អ្វីដល់ការរស់នៅ និងប្រកបរបរប្រចាំថ្ងៃរបស់ប្រជាជនទេ ទាំងព្រៃស្រោងសើម ទាំងសត្វព្រៃសុទ្ធតែជាប្រភេទធម្មជាតិមានប្រយោជន៏ដែលចាំបាច់ត្រូវតែគ្រប់គ្រងថែរក្សានិងការពារអោយបានម៉ឹងម៉ាត់ទុកជាប្រយោជន៏អោយកូនចៅជំនាន់ក្រោយៗទៀត។

- ព្រៃអារក្សជាប្រភេទព្រៃសំរាប់ការគោរពបូជាតាមបែបវប្បធម៌ជនជាតិភាគតិច ដូច្នេះព្រៃនេះជាប្រភេទព្រៃមិនអាចខ្វះបានសំរាប់សង្គមរស់នៅនៃប្រជាជនក្នុងតំបន់។ ថ្វីត្បិតព្រៃស្រោងសើមវាសំបូរ ទៅដោយឈើប្រណិតៗក៏ពិតមែនតែព្រៃនេះក៏មិនអាចប្រើប្រាស់ឬកាប់ទន្ទ្រានបានដែរ។ វាមានផលចំណេញដោយព្រៃត្រូវបាន ថែរក្សាកង់វង្ស តែវាមានផលមិនសូវល្អដោយយកព្រៃស្រោងធ្វើជាព្រៃអារក្ស ។

- មានប្រភេទព្រៃរបោះនិងដីកសិកម្មពនេចរ ខ្លះជាប្រភេទដីមានជីជាតិខ្ពស់អំណោយផលដល់ដំណាំស្រូវទាំងនៅរដូវប្រាំងនិងរដូវវស្សាដោយផ្តល់អោយកសិករនូវទិន្នផលស្រូវខ្ពស់ កត្តាទាំងនេះហើយដែលការប្រែប្រួលដីត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៏ដល់ការប្រកបរបរធ្វើស្រែនៅក្នុងឃុំ ព្រោះថាប្រជាពលរដ្ឋ១០០% សុទ្ធសឹងជាអ្នកស្រែ។ បើប្រៀបធៀបនឹងការធ្វើកសិកម្មពនេចរ ការធ្វើស្រែវាផ្តល់ផលខ្ពស់ហើយឆ្លើយតបតំរូវការនៃការរស់នៅផងដែរ។

- កសិកម្មពនេចរ ផ្តល់ផលប្រយោជន៏សំរាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃដូចជាបន្លែគ្រឿងទេស ផ្លែឈើ... ដែលត្រូវតែមានមិនអាចខ្វះបានគេក៏មិនអាចមានតែស្រែហើយពុំមានចំការនោះទេ។ក្នុងន័យនេះដីដែលមានជីជាតិធនល្អមសមស្របដំណាំចំការឃុំបានគិតគូរយកព្រៃរបោះមួយកន្លែងមកធ្វើជាដីកសិកម្មពនេចរព្រោះការប្រើប្រាស់ព្រៃ របោះវាក៏មិនសូវមានផលប្រយោជន៏ប៉ុន្មានទេ។

### ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត (A3)

## ៣.២.៣ បញ្ញត្តិលើការប្រើប្រាស់ដី

ជាធម្មតាការកំណត់នៃការប្រើប្រាស់ដីពេលអនាគត ចាំបាច់ត្រូវតែគោរពអោយបានទៅតាមផែនការដែលគ្រោងហើយដែលបានឯកភាពគ្នាក្នុងការប្រើប្រាស់ទៅតាមប្រភេទនិមួយៗ:

### ៣.២.២.១ កន្លែងកប់ខ្មោច

**•ក្បាលដី ១៣២០**

-ដីកប់ខ្មោចមានទំហំសរុប ៥.១៦៩៧ហត សំរាប់ឆ្នាំ២០២២ ប្រើប្រាស់សំរាប់ជាកន្លែងកប់ខ្មោចរបស់ប្រជាជនក្នុងឃុំព្រោះខ្មោចដែលស្លាប់ទៅគឺមិនមានការបូជាដូចជាជនជាតិខ្មែរនោះទេ។ ដីប្រភេទនេះមិនមានការហាមឃាត់តឹងតែងទេបរិវេណដីកប់ខ្មោចប្រជាជនអាចប្រើប្រាស់នូវធនធានធម្មជាតិខ្លះៗដូចជា វ័រ ផ្តៅ វំពាក់ កូនឈើតូចៗ។ល ។តែក៏មិន អោយកាប់រានដីដើម្បីធ្វើស្រែឬចំការនោះទេ។

### ៣.២.២.២ ដីអភិរក្សសត្វព្រៃ

**•ក្បាលដី ៦៦០០**

- ដីអភិរក្សសត្វព្រៃជាដីពោពេញទៅដោយព្រៃស្រោងសើមនិងព្រៃចំរុះគ្រប់ប្រភេទដែលជាជំរកនៃពពួកសត្វគ្រប់ប្រភេទរស់នៅព្រោះតំបន់នេះអំណោយផល ដល់ការរស់នៅដូចជាចំណីអាហារមានអូរផ្តល់ទឹក ព្រៃមានភាពអនុគ្រោះដល់ជីវិតសត្វទាំងឡាយ ។ទំហំព្រៃមានចំនួន២២២ហត ជាដីទទួលស្គាល់ដោយច្បាប់ មានការហាមឃាត់តឹងរ៉ឹង និងការពារយ៉ាងម៉ឺងម៉ាត់មិនមាននរណាមួយអាចប្រើប្រាស់ខុសពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនៃការប្រើប្រាស់ដែលបានចែងនៅកន្ទុងតំបន់ការពារនេះទេ។ ជនណាប្រព្រឹត្តិល្មើសនឹងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងត្រូវផាកពិន័យឬដាក់ទោសទៅតាមទំហំកំហុសដែលបានធ្វើ។

### ៣.២.២.៣ ព្រៃអារក្ស

**•ក្បាលដី ៣៧៤០**

-ព្រៃអារក្សប្រើសំរាប់គោរពតាមទំនៀមទំលាប់ប្រពៃណីមានទំហំ ១២ហត បានមកអំពីមួយផ្នែកនៃព្រៃស្រោងសើម។ ការប្រតិបត្តិនៅតំបន់នេះស្រដៀងគ្នានឹងតំបន់អភិរក្សសត្វព្រៃដែរពោលគឺការប្រើប្រាស់ទៅបានលុះត្រាគោរពតាមប្រពៃណីតំនៀមទំលាប់នៃជនជាតិនៅក្នុងតំបន់ ដូចជាការបន់ស្រន់ សែនព្រេន និងតំណមផ្សេងៗ មិនអនុញ្ញាតអោយចូលព្រៃរុករកភោគផលផ្សេងៗដែលមាននោះឡើយ។

### ៣.២.២.៤ ដីស្រែវស្សា

**•ក្បាលដី ២១១០**

- ដីស្រែវស្សាប្រើសំរាប់ដំណាំស្រូវមានទំហំ២០៣ហ.ត បានមកអំពីព្រៃរបោះមួយកន្លែងនិងអំពិដីកសិកម្មពនេចរចំនួន២កន្លែង ។ដីប្រភេទនេះអាចប្រើបានសំរាប់ដំណាំស្រូវនិងដំណាំបន្ទាប់បន្សំមួយចំនួនផ្តល់ដល់ការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។មិនអនុញ្ញាតអោយយកដីនេះទៅអភិវឌ្ឍន៍អ្វីផ្សេងក្រៅពីដំណាំស្រូវ ព្រោះស្រូវជាប្រភពស្បៀងអាហារដ៏សំខាន់បំផុតរបស់ប្រជាជននៅទីនោះ ហើយពួកគាត់មិនអាចធ្វើអ្វីផ្សេងបាន។

**៣.២.២.៥ ដីកសិកម្មពនេចរ**

**•ក្បាលដី ២៤០០**

-ដីកសិកម្មពនេចរមានទំហំ ៦២ហិកតា ប្រើសំរាប់ដាំដំណាំចំការវិលជុំដែលបានប្រែក្លាយមកអំពីព្រៃរបោះមួយកន្លែង ដើម្បីដាំជាដំណាំ ចេក ម្ទេស ស្លឹកគ្រៃ សាឡាត់ ខាត់ណា ស្ពៃ...។ កសិកម្មពនេចរជាទំលាប់នៃការធ្វើចំការដែលមានតាំងពីយូរយារណាស់មកហើយហើយដែលប្រជាជននៅក្នុងតំបន់ត្រូវការជាចាំបាច់ដើម្បីបានផលដំណាំសំរាប់ផ្គត់ផ្គង់ជីវភាពផង និងដើម្បីលក់យកកំរៃបង្កើនសេដ្ឋកិច្ចគ្រួសារផងដែរ ។ ដូច្នេះដីកសិកម្មពនេចរជាប្រភេទដីដែលមិនអាចយកទៅប្រើប្រាស់ធ្វើអ្វីផ្សេងបានទេ ព្រោះការប្រកបរបរកសិកម្ម គឺត្រូវមានទាំងស្រែ ទាំងចំការ ហើយស្ថានភាពសេដ្ឋកិច្ចក្នុងឃុំពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម។

ឃុំកាចូន,ថ្ងៃ...02...ខែ...04...ឆ្នាំ២០១០

**មេឃុំ**

ឆាយ_សុំ

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តរតនគីរី

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

វើនសៃ ថ្ងៃ ...05...ខែ...04...ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកវើនសៃ**

ជុំ_ទិល

**បានឃើញ និង ឯកភាព**

រតនគីរី ថ្ងៃ ...21...ខែ...05...ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តរតនគីរី**

ប៉ាវ_ហមផាន

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖  ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២៖  ស្ថានភាពនៃការគ្រប់គ្រង  និងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ៣៖  បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន្ធ៤៖  ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍

ឧបសម្ព័ន្ធ៥៖  បញ្ជីគំរោង

ឧបសម្ព័ន្ធ៦៖  ផែនទីប្រើប្រាស់ដីលំអិតនៅក្នុងឃុំ

ឧបសម្ព័ន្ធ៧៖  ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំ

ឧបសម្ព័ន្ធ៨៖  ផែនទីប្រើប្រាស់ដីអនាគតនៅក្នុងឃុំ  ឆ្នាំ២០០៩-២០២២

# ឧបសម្ព័ន ១

# ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅដ្ឋានភូមិ :**

### ដីភូមិលាយសួនដំណាំ :

ដីភូមិលាយសួនដំណាំ នៅក្នុងមូលដ្ឋានឃុំកាចូនគឺជាដីស្ថិតនៅតាមដងទន្លេសេសាន្តសងខាង ដែលមានស្ថានភាព ជាដីខ្ពង់រាបពីធម្មជាតិតាំងពីដូនតារៀងតមក ។ ដីភូមិនេះត្រូវបានដាំនូវដំណាំរួមផ្សំជាច្រើន ដូចជា ចេក ដូង ដំឡូង ស្វាយ ល្ហុត ខ្នុរ ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ....។ ល ។ក្រៅពីនេះ ដីភូមិលាយសួនដំណាំ មួយភាគជាដី ស្ថិតនៅជាប់គ្នា តាមបណ្តោយផ្លូវលំឬផ្លូវក្រាលគ្រួសក្រហម ។

ស្ថានភាពជាក់ស្តែងនៅឃុំកាចូនគឺការអំណោយផលដោយធម្មជាតិព្រោះដីភូមិលាយសួនដំណាំនេះបាន ទទួលឥទ្ធិពលពីទឹកទន្លេសេសាន្ត ដែលអាចអោយប្រជាជនដាំដំណាំបានទាំងរដូវប្រាំងនិងរដូវវស្សា ។ចំណែកដីលាយសួនដំណាំនៅតាមដងផ្លូវវិញគឺមានតិចតួចនៅរដូវប្រាំង ។

### ដីភូមិលាយស្រែ :

ដីប្រភេទនេះ គឺជាដីដែលភាគច្រើនជាដីភូមិដែលស្ថិតនៅ ជាប់ៗគ្នា ហើយជាធម្មតាដីភូមិបែបនេះ តែងតែមានដីស្រែស្ថិតនៅផ្នែកខាងក្រោយនៃដីភូមិ ។ ប្រភេទដីភូមិលាយស្រែនេះ ភាគច្រើននៃប្រជាពលរដ្ឋនៅឃុំកាចូនប្រើសំរាប់តែធ្វើស្រែនៅរដូវវស្សាតែមួយមុខគត់ ពោលគឺពុំមានប្រើប្រាស់សំរាប់ដំណាំអ្វីផ្សេងនោះទេ ។ជាទូទៅដីស្រែប្រភេទនេះមានទំហំពី ១ហិកតា ទៅ ១.៥ហិកតា ប៉ុណ្ណោះ ។

ដូច្នេះបើពិនិត្យទៅលើលទ្ធភាពនៃការប្រើប្រាស់ដីឃើញថា ពឹមានតុល្យភាពទៅនឹងកំណើននិងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនោះទេ ប្រការនេះឃុំបានគិតគូរក្នុងការបង្កើនផលិផលលើវិស័យកសកម្មដោយស្នើសុំអោយមានវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មអោយបានដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

- **ដីស្រែវស្សា :**

### ដីស្រែវស្សា ( ស្រូវសន្ទូង ) :

ដីស្រែវស្សានៅឃុំកាចូនត្រូវបានប្រើប្រាស់ សំរាប់តែការធ្វើស្រែវស្សាតែមួយមុខគត់ ពុំមានធ្វើស្រែប្រាំងទេ ការធ្វើស្រែវស្សារបស់ប្រជាជន គឺពឹងផ្អែក ទៅលើទឹកភ្លៀងជាធំ ប៉ុន្តែក៏មានស្រែមួយចំនួនដែលស្ថិតជិត ប្រភពទឹក បានប្រើប្រាស់ប្រភពទឹកដូចជាទន្លេ អូរសំរាប់ផ្តល់ទឹកចូលស្រែនៅរដូវរាំងស្ងួត ដែលអាចកើតមានជាយថាហេតុ ។ ក្នុងការធ្វើស្រែវស្សានេះ កសិករពុំមានប្រើប្រាស់ជីគីមីទេ គឺប្រើជីបានមកពីធម្មជាតិដូចជា ជីបានមកពីលាមកសត្វគោ-ក្របីជាដើម ។ផលិតផលស្រែវស្សាជាមធ្យមគឺពី១.៥តោនទៅ១.៨តោនក្នុងមួយហិកតាដី ដោយប្រើនូវប្រភេទស្រូវស្រាលដូចជា នាងខូន ក្រចកចាប ប្រវិកស ហើយនិងស្រូវធ្ងន់ដូចជា នាងនូ ក្រមួនស សូមាលី ។ឯស្រូវកណ្តាលរួមមាន ស្រូវដំណើប ចំបើងលឿង ប្រកិន ផ្កាខ្ញី ។ផ្ទៃដីស្រូវវស្សាសរុបនៅឃុំនេះគឺ

៣៣៧ហិកតា ។ពេលវេលាសំរាប់ធ្វើស្រូវវស្សាមានរយៈពេល ៧ខែគឺចាប់ពីដើមខែឧសភារហូតដល់ដំណាច់ខែវិច្ឆិកា

ដីស្រែវស្សាបច្ចុប្បន្ន ពុំទាន់ឆ្លើតតបបានទៅនឹងសេចក្ដីត្រូវការប្រើប្រាស់អោយអស់លទ្ធភាពនៅឡើយ ព្រោះវា នៅមានបញ្ហាចោទ លើការខ្វះទឹក ពេលរាំងស្ងួត ដែលជាហេតុ ធ្វើអោយប្រជាជន មិនអាចធ្វើស្រែបាន ហើយស្រូវមានការស្វិតខូច មិនទទួលបាននូវទិន្នផល ។ មូលហេតុទាំងនេះបណ្ដាលមក ពីខ្វះប្រពន្ធ័ស្រោចស្រព សំរាប់ផ្ដល់ទឹក ពេលខ្វះទឹកនៅកូនរដូវប្រាំង ឬការរាំងស្ងួត ។

- **ដីកសិកម្មពនេចរ :**

ដីកសិកម្មពនេចរសំដៅលើដីចំការផ្លាស់វេនដំណាំដែលក្នុងនោះរួមមានចំការដំណាំស្រូវនិងដំណាំរួមផ្សំផ្សេងៗទៀតរួមមានបន្លែបង្កាគ្រប់ប្រភេទ និងមិនមានអោយដាំដំណាំដើមឈើហូបផ្លែនិងដំណាំយុទ្ធសាស្ត្រទេ ព្រោះដីចំការវិលជុំនេះពួកគាត់ធ្វើតែរយៈពេល២ឆ្នាំប៉ុណ្ណោះ ដែលក្នុងឆ្នាំទី១ដំណាំស្រូវទទួលបានលទ្ធផលខ្ពស់ ចំណែកនៅឆ្នាំទី២ផលស្រូវថយចុះបើធៀបនឹងឆ្នាំទី១ ។ បន្ទាប់ពីនោះគឺពួកគាត់បន្តទៅធ្វើនៅកន្លែងផ្សេងទៀត ដែលដីនោះបានបោះបង់អស់រយៈពេល ៥ឆ្នាំមុននេះ បានក្លាយជាដីដុះដើមឈើឡើងវិញនិងមានជីវជាតិ ។

ដីកសិកម្មពនេចរគឺសំរាប់បងប្អូនជនជាតិភាគតិចដែលការគ្រប់គ្រងនិងកាន់កាប់ទៅតាមជំនឿ និងប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ។ចំការប្រភេទនេះច្រើកាប់នៅចំងាយពី២គ.មទៅ៣គ.មពីភូមិ ហើយចំការប្រភេទនេះពេលអនាគតនឹងក្លាយទៅជាដីលំនៅដ្ឋានអចិន្ត្រៃយ៍របស់ប្រជាពលរដ្ឋនៅក្នុងឃុំ ។

- **ព្រៃស្រោងសើមៈ**

ព្រៃស្រោងសើមជាប្រភេទព្រៃញ៉ាតមានឈើធំៗនិងមានច្រើនស្រទាប់ហើយរក្សាស្លឹករបស់វាបានពេញមួយឆ្នាំ ហើយព្រៃប្រភេទនេះច្រើនមាននៅតំបន់ភ្នំ និងនៅតាមមាត់ស្ទឹង ទន្លេ ។

- **ព្រៃរបោះ**

ព្រៃនេះរួមបញ្ចូលព្រៃរបោះចំរុះស្ងួត និងប្រភេទព្រៃ DIPTERCARP ស្ងួត ។ព្រៃរបោះជ្រុះស្លឹកស្ទើរតែទាំងស្រុងនៅរដូវប្រាំង ។ព្រៃប្រភេទនេះងាយទទួលការឆេះ បើប្រៀបធៀបនឹងប្រភេទព្រៃផ្សេងទៀត ។លក្ខណៈធម្មជាតិព្រៃ DIPTERCARP ស្ងួតមានភាពរហាលឬចំហរ ប្រសិនបើពុំមានការរំខាន ព្រៃរបោះ អាចមានគំរបកន្សោមស្លឹកត្រឹមតែ៤០%ដី និងវាលស្មៅអាចមានឥទ្ធិពលសំខាន់លើការសំគាល់ព្រៃប្រភេទនេះ ។នៅរដូវ ប្រាំង វាមានការពិបាកក្នុង ការញែកប្រភេទព្រៃរបោះចេញពីព្រៃគម្លោច ។

- **ព្រៃចំរុះ(ស្រោងនិងរបោះ):**

ព្រៃប្រភេទនេះជាការរាប់បញ្ចូលព្រៃស្រោងនិងប្រភេទឈើនៃព្រៃរបោះ ហើយភាគរយនៃព្រៃស្រោងប្រែប្រួលពី៣០%ទៅ៧០% ។ព្រៃចំរុះមានពណ៌បៃតងពេញមួយឆ្នាំទោះបីជាព្រៃរបោះមានច្រើនលើសលប់ក៏ដោយ

- **ព្រៃដុះឡើងវិញ:**

ព្រៃដុះឡើវិញគឺជាព្រៃបានមកពីស្រទាប់កូនឈើតូចៗដែលដុះឡើងវិញជាថ្មី បន្ទាប់ពីបានកាប់រានធ្វើចំការ

ពនេចរអស់មួយរយៈពេលមក អាចនិយាយបានថាជាតំបន់នៃដំណុះព្រៃចាស់ៗឡើងវិញ ។

- **ចំការបោះបង់ដុះស្មៅ:**

ចំការបោះបង់ដុះស្មៅប្រហាក់ប្រហែលនឹងព្រៃដុះឡើងវិញដែរ គឺសំដៅចំការពនេចរដាំស្រូវចំការនៅរដូវវស្សា ក្នុងអំឡុងពេលបោះបង់ពី៥ ទៅ៧ឆ្នាំ បានដុះស្មៅនិងដើមឈើតូចៗជាច្រើន ។

- **ព្រៃគម្ពោធ:**

ព្រៃគម្ពោធគឺជាដីមិនមែនព្រៃដែលរួមមានព្រៃគម្ពោធបៃតងជានិច្ច និងព្រៃគម្ពោធស្ងួត ។ព្រៃគម្ពោធបៃតងជានិច្ច ជាការដុះលាយនៃពពួកចុល្លព្រឹក្សក្រាស់ វាលស្មៅ និងដើមឈើដែលគំរបកន្សោមស្លឹកក្រោម២០% ។ ព្រៃប្រភេទនេះឃើញមានភាគច្រើននៅតំបន់ដីរាក់ៗ នៅលើកំពូលភ្នំក្រោមលក្ខខ័ណ្ឌអាកាសធាតុ ឬជាលទ្ធផលនៃការប្រើប្រាស់ដីមិនមាននិរន្តរភាព ។ព្រៃប្រភេទនេះអាចក្លាយទៅជាព្រៃធំៗឡើងវិញបាន ។

- **ចំការបោះបង់ដុះព្រៃគម្ពោធ:**

ចំការបោះបង់ដុះព្រៃគម្ពោធ គឺជាចំការចាស់ដែលបោះបង់ក្នុងរយៈពេលពី៥ទៅ៧ឆ្នាំ វាបានដុះចេញជាដើមឈើតូចៗជាច្រើនលាយឡំគ្នា ដែលដើមឈើនោះអាចក្លាយព្រៃធំៗបាន ។

- **ដីខ្សាច់:**

ដីខ្សាច់ភាគច្រើនជាដីពុំសូវមានជីជាតិដល់ដំណាំកសិកម្មនោះទេ ដីប្រភេទនេះជាដីដែលទុកសំរាប់ជាដីលំនៅដ្ឋានឬសាងសង់ជាកន្លែងផ្សេងៗសំរាប់បំរើការសង្គម ។

- **អូរ ទន្លេ:**

ទន្លេជាមួយផ្នែកនៃទន្លេសេសាន្ត ដែលភាគច្រើនមានទឹករាក់នៅរដូវប្រាំង នៅរដូវវស្សាទឹកឡើងកំពស់ខ្លាំងដែលជាហេតុបណ្តាលអោយប៉ះពាល់ដល់ប្រជាជនស្ថិតនៅតាមដងទន្លេ និងប៉ះពាល់ដល់ផលដំណាំកសិករ ។ ក្រៅពីទន្លេនៅមានអូរជាច្រើនទៀតដែលជាប្រភពទឹកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃនិងជាប្រភពសំរាប់ប្រើប្រាស់សំរាប់ដំណាំ ចំការនិងស្រែផងដែរ ។

| លរ | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| 1 | Code : 1200 ដីលំនៅដ្ឋានភូមិ |  |

| | | |
|---|---|---|
| 2 | Code : 2110<br>ស្រូវវស្សា : ធ្វើស្រែវស្សា |  |
| 3 | Code : 2120<br>ដីកសិកម្មពនេចរ |  |
| 4 | Code : 2200<br>ព្រៃស្រោងសើម |  |
| 5 | Code : 2200<br>ព្រៃល្បោះ |  |

| | | |
|---|---|---|
| 6 | ព្រៃចំរុះ( ស្រោង និងរបោះ) |  |
| 7 | ចំការបោះបង់ដុះស្មៅ |  |
| 8 | ព្រៃដុះឡើងវិញ |  |
| 9 | ព្រៃគម្លោផ |  |

| | | |
|---|---|---|
| 10 | ចំការបោះបង់ដុះព្រៃគម្ពោធ |  |
| 11 | ដីខ្សាច់ |  |
| 12 | អូរ-ស្ទឹង-ទន្លេ |  |

# ឧបសម្ព័ន្ធ ២
## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្តិ និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ព្រៃសហគមន៍អណ្តូងព្រះនាង | ដីសាធារណៈរបស់រដ្ឋ | ១.៤០៨ |
| | ចំការបោះបង់ដុះស្មៅ | ១កន្លែង | ២០ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | ១កន្លែង | ១៣៨ |
| | ព្រៃស្រោងសើម | ១កន្លែង | ៣៦៤ |
| | ព្រៃចំរុះ( ស្រោងនិងរបោះ) | ១កន្លែង | ៣៨៤ |
| | ព្រៃដុះឡើងវិញ | ១កន្លែង | ៤៨១ |
| | ព្រៃគម្ពោធ | ១កន្លែង | ២១ |
| ២ | ផ្នែកនៃទន្លេសេសាន | សាធារណៈរបស់រដ្ឋ | ផ្ទៃទឹក |

ប្រភព: ទិន្នន័យ GIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តរតនគិរី

# ឧបសម្ព័ន្ធ ៣

## បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| បាត់បង់ព្រៃឈើ | បានហ្វាំង, ប៉ុង | -ការកាប់បំផ្លាញព្រៃឈើខុសច្បាប់<br>-ការកាប់ចំការវិលជុំ | -ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ដាំកូនឈើឡើងវិញ។<br>-ពង្រឹងច្បាប់ការពារព្រៃឈើ។<br>-ទប់ស្កាត់ការជួញដូរសត្វព្រៃ។<br>-ទប់ស្កាត់ការកាប់ព្រៃឈើជំរកសត្វព្រៃ។<br>-ផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃ ឈើ និងសត្វព្រៃ។ |
| ទំនាស់ដីធ្លី | បានហ្វាំង, ប៉ុង | - បាត់បង់ព្រំប្រទល់ពីឃុំនិងឃុំ<br>- កំណត់ព្រំប្រទល់មិនទាន់ច្បាស់លាស់ | -បង្កើតគណៈកម្មការដោះស្រា ទំនាស់ដីធ្លី។<br>-ចេញប័ណ្ណកាន់កាប់ដីធ្លី។ |
| សត្វព្រៃថយចុះ | បានហ្វាំង, ប៉ុង | -គ្មានការទប់ស្កាត់បំផ្លាញព្រៃឈើ<br>-គ្មានការទប់ស្កាត់ការជួញដូរសត្វព្រៃ | -ទប់ស្កាត់ការកាប់ព្រៃឈើជំរកសត្វព្រៃ។<br>-ផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃឈើ និងសត្វព្រៃ។<br>-ទប់ស្កាត់ការជួញដូរសត្វព្រៃ |

| | | | |
|---|---|---|---|
| | | | -ដាំកូនឈើឡើងវិញ។ |
| **ត្រីថយចុះ** | បានហ្វាំង, ប៉ុង | -ខ្វះការការពារបឹងធម្មជាតិ<br>ការបំពុលឆក់ត្រីខុសច្បាប់ | -អភិរក្សបឹង។<br>-ពង្រឹងច្បាប់ជលផល។<br>-ពង្រឹងគណៈកម្មការជលផល។ |
| **ទិន្នផលស្រូវថយចុះ** | បានហ្វាំង, ប៉ុង | -ដីខ្សោះជីជាតិ គ្មានទឹកស្រោចស្រព | ផ្តល់ម៉ាស៊ីនបូមទឹក។<br>ជីកប្រឡាយទឹក។<br>ភ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់។<br>បណ្តុះបណ្តាលកសិករធ្វើជីកំប៉ុស្តិ៍។ |

# ឧបសម្ព័ន្ធ ៤

# ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងចំរើសនៃការប្រើប្រាស់ដីធ្លីអនាគត

# កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើ ផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចេះបច្ចេកទេសក្នុងការធ្វើផលិតកម្មដំណាំស្រូវ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំកាចូន ស្រុក វើនសៃ ខេត្ត រតនគិរី | ប្រជាជនប្រមាណ៥០%យល់ដឹងពីបច្ចេកទេសធ្វើផលិតកម្មដំណាំស្រូវអោយទទួលបានទិន្នផលខ្ពស់ | កែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ | ផ្តល់ម៉ាស៊ីនបូមទឹកដីកប្រឡាយ<br>ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់<br>បណ្តុះបណ្តាលកសិករធ្វើជីកំប៉ុស្តិ<br>អភិរក្សបឹង | |
| មានផ្លូវងាយស្រួលក្នុងការធ្វើដំណើរ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំកាចូន ស្រុក វើនសៃ ខេត្ត រតនគិរី | ប្រជាពលរដ្ឋមានផ្លូវងាយស្រួល ក្នុងការធ្វើទំនាក់ទំនង និងប្រកបមុខរបរបានល្អប្រសើរ | កែលំអហេដ្ឋារចនាសម្ព័ន្ធផ្លូវលំ និងស្ថាបនាឡើងវិញ | ជួសជុលផ្លូវលំក្រាលគ្រួសក្រហម<br>សាសង់ផ្លូវលំក្រាល គ្រួសក្រហម<br>ជួសជុលស្ពានឆ្លងអូរ | |

| | | | | | |
|---|---|---|---|---|---|
| | | | | សាងសង់ស្ពានឆ្លងអូរ<br>សាងសង់លូរកាត់អូរ | |
| សហគមន៍មានសុខភាពនិងផ្តល់សេវាបានល្អ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ កាចូន ស្រុក វើនសៃ ខេត្ត រតនគីរី | ប្រជាពលរដ្ឋទទួលបានសេវា សុខ ភាពនិងមានសុខភាពល្អប្រសើរ | កាត់បន្ថយអត្រាគ្រោះថ្នាក់របស់ប្រជាជនក្នុងសហគមន៍<br>កាត់បន្ថយអត្រាគ្រោះថ្នាក់របស់ស្ត្រីនិងកុមារ | ផ្សព្វផ្សាយអប់រំសុខភាពអនាម័យដល់សហគមន៍<br>អប់រំសុខភាពអនាម័យនៃការប្រើប្រាស់ទឹកស្អាត<br>សាងសង់អណ្តូងស្នប់<br>សាងសង់បង្គន់អនាម័យ<br>ផ្តល់ថ្នាំអាប៉ែតដាក់ទឹកប្រើប្រាស់ | |
| កុមារគ្រប់អាយុបានចូលរៀន | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ កាចូន ស្រុក វើនសៃ ខេត្ត រតនគីរី | អនាគតកុមារមានចំណេះដឹង និង មានធនធានមនុស្សល្អប្រសើរ | លើកកំពស់វិស័យអប់រំ | សាងសង់សាលារៀន<br>បណ្តុះបណ្តាលគ្រូអប់រំក្រៅប្រព័ន្ធបន្ថែម<br>បើកថ្នាក់អក្ខរៈកម្មតាមភូមិ | |
| បង្កើតមជ្ឈមណ្ឌលវប្បធម៌និងទេសចរណ៍ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ កាចូន ស្រុក វើនសៃ ខេត្ត រតនគីរី | ប្រជាពលរដ្ឋទទួលបាននូវការថែ ទាំផ្នែកវប្បធម៌ ទំនៀមទំលាប់ ប្រពៃណី បង្កើនទេសចរណ៍ | រៀបចំនិងពង្រីកមជ្ឈមណ្ឌលវប្បធម៌ ទេសចរណ៍ | បង្កើតមជ្ឈមណ្ឌលវប្បធម៌ទេសចរណ៍<br>ផ្សព្វផ្សាយច្បាប់ចរាចរណ៍<br>បណ្តុះបណ្តាលការទំនាក់ | |

| | | | | | |
|---|---|---|---|---|---|
| | | | | ទំនងភ្ញៀវទេសចរណ៏<br>សហគមន៏ | |
| ព្រៃឈើនិងសត្វព្រៃនៅគង់វង្ស | | ពេលអនាគតប្រជាពលរដ្ឋទទួល<br>បានផលអនុផលព្រៃឈើ<br>សត្វព្រៃ ហូបចុកនិងលក់បាន<br>កំរៃជាប្រចាំ | ពង្រឹងវិស័យព្រៃឈើនិងសត្វព្រៃ | ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ<br>ពង្រឹងច្បាប់ការពារព្រៃឈើ<br>ទប់ស្កាត់ការជួញដូរសត្វព្រៃ<br>ទប់ស្កាត់ការកាប់ឈើជំរកសត្វ<br>ផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃឈើ សត្វព្រៃ | |
| ធនធានមច្ឆាជាតិត្រូវបានអភិរក្ស | | អនាគតសំបូរពូជត្រីគ្រប់ប្រភេទសំរាប់ជាតំរូវការជីវភាពប្រចាំថ្ងៃ<br>មានធនធានមច្ឆាយូរអង្វែង | ពង្រឹងវិស័យជលផល | ពង្រឹងគណៈកម្មការជលផល | |
| មានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ | | កាត់បន្ថយទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋនិងទទួលបានកម្មសិទ្ធិ | ពង្រឹងច្បាប់ភូមិបាល | ផ្សព្វផ្សាយច្បាប់ភូមិបាលអោយដល់សហគមន៏<br>ចេញប័ណ្ណកានកាប់ដីធ្លី | |

# ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ (១) | ៥ឆ្នាំទី២ (២) | ៥ឆ្នាំទី៣ (៣) | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ ( ១ ខ្សែ ) | ១២ | គ.ម | ៥ | ៥ | ២ | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហម ( ២ ខ្សែ ) | ១២ | គ.ម | ៥ | ៥ | ២ | |
| | ១.១.៣. ជួសជុលផ្លូវក្រាលគ្រួសក្រហម( ១ ខ្សែ ) | ៧ | គ.ម | ៧ | 0 | 0 | |
| | ១.១.៤. ផ្លូវរទេះ/ថ្មើជើង | 0 | 0 | 0 | 0 | 0 | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ | ៣ | គ.ម | ៣ | 0 | 0 | |
| | ១.២.២. ប្រឡាយរង | ៦,៧ | គ.ម | 0 | 0 | 0 | |

---

(១) - ៥ឆ្នាំទី១ (២00៨-២០១២): បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២00៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

(២) - ៥ឆ្នាំទី២ (២០១៣-២០១៧): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

(៣) - ៥ឆ្នាំទី៣ (២០១៨-២0២២): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | 0 | កន្លែង | 0 | 0 | 0 | |
| | ១.៣.២. ចំនួនស្ពានឈើ | ៥ | កន្លែង | ៥ | 0 | 0 | |
| | ១.៣.៣. ចំនួន ទ្វារទឹក | 0 | កន្លែង | 0 | 0 | 0 | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ | ៤ | កន្លែង | ៤ | 0 | 0 | |
| | ១.៣.៥. ផ្សេងៗ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ១ | អាគារ | 0 | 0 | ១ | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | 0 | អាគារ | 0 | 0 | 0 | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ១ | អាគារ | 0 | 0 | ១ | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. មណ្ឌលសុខភាព | 0 | កន្លែង | 0 | 0 | 0 | |
| | ២.៦.១.៥. ប៉ុស្តិសុខភាព | ១ | កន្លែង | 0 | 0 | ១ | |
| | ២.៦.១.៦. ស្រះទឹកស្អាត | 0 | ស្រះ | 0 | 0 | 0 | |
| | ២.៦.១.៧. អណ្តូងទឹកស្អាត | ៦ | អណ្តូង | ៦ | 0 | 0 | |
| | ២.៦.១.៨. កន្លែងចាក់សំរាម | 0 | កន្លែង | 0 | 0 | 0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | ១ | កន្លែង | ១ | 0 | 0 | |
| | ២.៦.១.៤.២. ទីតាំងផ្សារ | 0 | កន្លែង | 0 | 0 | 0 | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥.២. វត្តព្រះអារាម | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥.៣. សាលាឆទាន | 0 | 0 | 0 | 0 | 0 | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. តំបន់អភិរក្សសត្វព្រៃ | ១៨៧២ | ហិកតា | ១៨៧២ | 0 | 0 | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ៩២ | ហិកតា | ៨0 | ៨0 | ៨៥ | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | ៧ | ហិកតា | ៧ | 0 | 0 | |
| | ២.៦.២.២.៣. ដីវាលស្រែ | ១៩៩ | ហិកតា | ៥៩ | ៧0 | ៧0 | |
| | ២.៦.២.២.៤. ព្រៃអារក្ស | ១៨៤ | ហិកតា | ១២ | 0 | 0 | |
| | ២.៦.២.២.៥. ដីកសិកម្មពនេចរ | ៦២ | ហិកតា | ៦២ | 0 | 0 | |
| | ២.៦.២.២.៦. ផ្សេងៗ | | | | | | |